សមាសភាគកសាងផែនការបន្សាំ និងភាពធន់នៅតំបន់ឆ្នេរ

# គោលការណ៍ណែនាំសម្រាប់បញ្ចូលការគិតគូរអំពីការប្រែប្រួល អាកាសធាតុទៅក្នុងការកសាងផែនការអភិវឌ្ឍន៍ឃុំ




Cambodia Climate Change Alliance (CCCA)

Implemented by: Supported by:

Ministry of Environment

European Union

UNDP
Empowered lives
Resilient nations

Danida

SWEDEN

UNEP-DHI CENTRE
for Water and Environment

UNEP

DHI


២០១៤

# បុព្វកថា

ខ្ញុំមានក្តីសោមនស្សរីករាយសូមបង្ហាញរបាយការណ៍ ស្តីពីការវាយតម្លៃភាពងាយរងគ្រោះនិងហានិភ័យពីការប្រែប្រួលអាកាសធាតុ នៃសហគមន៍ក្នុងតំបន់ឆ្នេរកម្ពុជាដែលជាសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការប្រកបដោយ ផ្លែផ្កាវវាងស្ថាប័នរដ្ឋគ្រប់កំរិត ដូចជា ថ្នាក់ខេត្ត ស្រុក និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ គម្រោង និងកម្មវិធី ដែលទាក់ទងជាមួយការអភិវឌ្ឍន៍តំបន់ឆ្នេរ និងការប្រែប្រួលអាកាសធាតុ ។ របាយការណ៍នេះ ជារបាយការណ៍មួយក្នុងចំណោមរបាយការណ៍ដ៏ទៃទៀតដែលនឹងរៀបរាប់សង្ខេបពីសកម្មភាពអនុវត្តគម្រោងនិងវិធីសាស្ត្រ ដើម្បីបញ្ជ្រាបសកម្មភាព និងវិធីសាស្ត្រការបន្សាំការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងរៀបចំរចនាសម្ព័ន្ធ និងកសាងសមត្ថភាព ដើម្បីអនុវត្តន៍វិធានការបន្សុំនឹងការប្រែប្រួលអាកាសធាតុ ។

របាយការណ៍នេះ ផ្តោតលើគោលការណ៍ណែនាំដើម្បីបញ្ចូលការគិតគូរលើបញ្ហាការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ឃុំនៅក្នុងប្រទេសកម្ពុជា ។ គោលការណ៍ណែនាំនេះ មានបំណងសម្រាប់ដាក់ឲ្យប្រើប្រាស់លើអនុសាសន៍ចំពោះទិន្នន័យដែលប្រមូលបានសម្រាប់ឃុំពាក់ព័ន្ធ និង សម្រាប់ប្រើប្រាស់នៅផែនការប្រែប្រួលអាកាសធាតុ ។

ភាពសម្បូរណ៍បែបនៃធនធានធម្មជាតិ និងបរិស្ថាននៅតំបន់ឆ្នេរសមុទ្រកម្ពុជា បានរងផលប៉ះពាល់រយៈពេលជាច្រើនឆ្នាំ ពីសកម្មភាពអភិវឌ្ឍន៍។ លើសពីនេះទៀត ការប្រែប្រួលអាកាសធាតុក៏បង្កឲ្យមានផលប៉ះពាល់ ដល់ជីវភាពរស់នៅតំបន់ឆ្នេរ សមុទ្រ ជាពិសេសតំបន់ទំនាបដូចជា ទឹកជំនន់ ការជ្រាបចូលទឹកសមុទ្រ និងការហូរច្រោះឆ្នេរ ។ សេចក្តីត្រូវការលើការកែលម្អលើការគ្រប់គ្រង ដើម្បីធានាដល់ការកែលម្អដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមនៅក្នុងតំបន់ដោយមិនបង្កឲ្យមានផលប៉ះពាល់ដល់ធនធានធម្មជាតិ និងបរិស្ថាន ជាពិសេសវាជាការបន្ទាន់ទាក់ទងនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុចំពោះជីវភាពរស់នៅនាពេលបច្ចុប្បន្ន ដែលសហគមន៍តំបន់ឆ្នេរកំពុងតែបង្កើតការបន្សុំ និងបង្កើនភាពធន់ដល់សហគមន៍ ។ នៅពេលជាមួយគ្នា គោលការណ៍ណែនាំមានសារៈប្រយោជន៍ អាចប្រើប្រាស់សម្រាប់អនុវត្ត និងពង្រីកទៅផ្នែកដ៏ទៃទៀតនៅ តំបន់ឆ្នេរ ព្រមទាំងខេត្តដ៏ទៃទៀត ។

របាយការណ៍នេះ មានសារៈសំខាន់ចំពោះអាជ្ញាធរឃុំ ស្រុក និងខេត្ត ព្រមទាំងមន្ទីរជំនាញនៅក្នុងខេត្តនៅតំបន់ឆ្នេរសមុទ្រកម្ពុជា ដើម្បីដោះស្រាយបញ្ហាស្មុគស្មាញទាក់ទងនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងការប្រែប្រួលអាកាសធាតុការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិប្រកបដោយចីរភាព ។ របាយការណ៍នេះ នឹងបង្ហាញពីសារប្រយោជន៍ដល់អ្នកអានមានដូចជាអ្នករៀបចំគោលនយោបាយនៅថ្នាក់ជាតិ អ្នកធ្វើផែនការ និងស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល គម្រោងផ្សេងៗ និងផ្នែក ឯកជន ព្រមទាំងជាមូលដ្ឋានដល់ការអប់រំ ការស្រាវជ្រាវផងដែរ ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អ្នកអានទាំងអស់នឹងស្វែងយល់ពីរបាយការណ៍នេះ ដែលជាធនធានដ៏មានតម្លៃសម្រាប់ការងារការប្រែប្រួលអាកាសធាតុនៅកម្ពុជា ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៤

**អគ្គនាយកបច្ចេកទេស**

**និងប្រធានគណៈកម្មាធិការដឹកនាំគម្រោង**

**ទេជ. ឡុញ ហ៊ាល**

# សេចក្តីថ្លែងអំណរគុណ


របាយការណ៍ ស្តីពីគោលការណ៍ណែនាំសម្រាប់បញ្ជូលការគិតគូរអំពីការប្រែប្រួលអាកាសធាតុទៅក្នុងការកសាងផែនការអភិវឌ្ឍន៍ឃុំនេះ ត្រូវបានរៀបរៀងឡើងនៅក្រោមសមាសភាគកសាងផែនការបន្សុំ និងភាពធន់ក្នុងតំបន់ឆ្នេរសមុទ្រកម្ពុជា ក្រោមកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា។ របកគំហើញក្នុង របាយការណ៍នេះបានផ្អែកលើមេរៀននានា ដែលទទួលបានពីសកម្មភាពដែលអនុវត្តនៅក្រោមសមាសភាគនេះ។

តាងនាមឲ្យក្រុមការងារតំបន់ឆ្នេរសមុទ្រកម្ពុជា ខ្ញុំបាទសូមសំដែងការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាអនុប្រធានគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដែលតែងតែជម្រុញ ណែនាំ និងគាំទ្រយ៉ាងខ្លាំងក្លាដល់កិច្ចប្រឹងប្រែងរបស់ក្រុមការងារ ដើម្បីសម្រេចបានរបាយការណ៍នេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ឯកឧត្តម លោក លោកស្រី ជាសមាជិកគណៈកម្មាធិការដឹកនាំគម្រោង ក្រុមការងារជនបង្គោលថ្នាក់ជាតិ ក្រុមការងារបច្ចេកទេសថ្នាក់ខេត្ត ទីប្រឹក្សាជាតិ និងអន្តរជាតិ រួមទាំងភាគីពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែកផ្តល់មតិល្អៗ ចំពោះការចងក្រងរបាយការណ៍នេះ ។

ជាចុងក្រោយ សូមថ្លែងអំណរគុណដល់កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ចំពោះការឧបត្ថម្ភគាំទ្រដល់សមាសភាគកសាងផែនការ និងភាពធន់ដល់ប្រែប្រួលអាកាសធាតុនៅតំបន់ឆ្នេរសមុទ្រកម្ពុជា តាមរយៈភ្នាក់ងារអនុវត្ត DHI សហការល្អជាមួយក្រសួងបរិស្ថាន។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៤

**គណៈកម្មាធិការដឹកនាំគម្រោង**

**អនុប្រធានអចិន្ត្រៃយ៍**

**បណ្ឌិត វ៉ាន់ មុនីនាថ**

# ជំពូកនានានៃឯកសារណែនាំនេះ

| ល.រ | ចំណងជើង | លទ្ធផល | តម្រូវការទិន្នន័យ |
|---|---|---|---|
| ១ | **សេចក្តីផ្តើម** | តើគោលការណ៍ណែនាំនេះធ្វើអ្វីនិងមិនធ្វើអ្វី | |
| ២ | **បរិបទនៃផែនការ** | ពិនិត្យមើលសំណើផែនការ/គម្រោង/គោលនយោបាយ នៅថ្នាក់ជាតិ ខេត្ត និង/ឬ ស្រុក ដែលអាចមានការពាក់ព័ន្ធមកលើឃុំ | ផែនការថ្នាក់ខ្ពស់ពីស្ថាប័ននានា |
| ៣ | **ការប្រើប្រាស់ទិន្នន័យស្ថិតិ** | ការស្វែងយល់អំពីរបៀបបកស្រាយទិន្នន័យឃុំ | ទិន្នន័យឃុំ (២០០៦-១២) |
| ៤ | **ចំនួនប្រជាជន** | ការស្វែងយល់អំពីការប្រែប្រួលនៃប្រជាជនក្នុងឃុំ ដែលទាក់ទងនឹងអត្រាកំណើន ព័ត៌មានអំពីគ្រួសារ ចំណាកស្រុក យេនឌ័រ និងក្រុមជនងាយរងគ្រោះ | ទិន្នន័យប្រជាជន (២០០៦-១២) |
| ៥ | **សេដ្ឋកិច្ច** | ការស្វែងយល់អំពីរចនាសម្ព័ន្ធសេដ្ឋកិច្ចឃុំ និងការប្រែប្រួលនៃរចនាសម្ព័ន្ធ និងមូលហេតុនៃការប្រែប្រួលនេះ | ទិន្នន័យសេដ្ឋកិច្ច (២០០៦-១២) |
| ៦ | **ផ្ទះសំបែងនិងសេវានានា** | ការស្វែងយល់អំពីការប្រែប្រួលគុណភាពផ្ទះសំបែងនិងការទទួលបានសេវានានា និងតើប្រែប្រួលបែបណា និងមូលហេតុនៃការប្រែប្រួល | ទិន្នន័យផ្ទះសំបែង និងសេវា (២០០៦-១២) |
| ៧ | **លទ្ធភាពចេញចូល** | ការស្វែងយល់ពីផ្លូវចេញចូលក្នុងឃុំ និងតើវាប្រែប្រួលបែបណា | ទិន្នន័យ (២០០៦-១២) |
| ៨ | **បញ្ហាដែលកំណត់ឃើញ** | ការពិនិត្យមើលបញ្ហាដែលបានកំណត់ឃើញពីមុនមក និងត្រូវបានឃុំបញ្ចូលក្នុងផែនទី និងដែលមានឥទ្ធិពលមកលើការរស់នៅ និងលក្ខខណ្ឌការងារក្នុងកន្លែងនោះ | ផែនទីបញ្ហានិងជំពូក ៣-៧ |
| ៩ | **ការកសាងផែនការប្រើប្រាស់ដី និងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ** | ការស្វែងយល់ពីថាតើការប្រែប្រួលអាកាសធាតុអាចតម្រូវឲ្យឃុំបន្សុាំនឹងការប្រែប្រួលកាៈទេសៈដោយរបៀបណា | ទិន្នន័យឋានលេខា និងជំពូក ៣-៨ |
| ១០ | **ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ** | ការពិនិត្យការត្រៀមលក្ខណៈរបស់ឃុំសម្រាប់ព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី | យោបល់ពីឃុំ |
| ១១ | **ជាតុចូលក្នុងការកសាងផែនការអភិវឌ្ឍន៍ឃុំ** | ផែនទីនិងសេចក្តីអធិប្បាយអំពីគម្រោងទៅអនាគតដែលឃុំចាត់ទុកថាពាក់ព័ន្ធក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ និងកង្វល់អំពីព្រឹត្តិការជាតុអាកាសមិនប្រក្រតីនៅក្នុងតំបន់នោះ។ | ផែនទីគម្រោងនិងជំពូល ៣-១០ |

## ក្រាហ្វិក


រូបទី ១. កំណើនចំនួនប្រជាជនក្នុងឃុំ និងទីជនបទក្នុងខេត្ត ........ ៨

រូបទី ២. គ្រួសារដែលមានស្ត្រីជាមេគ្រួសារ (២០០៦-១២) ........ ៩

រូបទី ៣. ការងារនៅក្រៅតំបន់នេះ (២០០៨-១២) ........ ១០

រូបទី ៤. ការប្រែប្រួលរបរចំបងប្រចាំគ្រួសារក្នុងស្រុកមណ្ឌលសីម៉ា (២០០៨-១០) ........ ១២

រូបទី ៥. ផ្ទះដែលមានដំបូលស្លឹកនៅស្រុកព្រៃនប់ (%នៃចំនួនសរុប) ........ ១៤

រូបទី ៦. ផ្ទះដែលមានអគ្គិសនីនៅព្រៃនប់ និងមណ្ឌលសីម៉ា (២០០៨-១២) ........ ១៥

រូបទី ៧. រដូវប្រាំង. ការទទួលបានទឹកស្អាត នៅស្រុកមណ្ឌលសីម៉ា ........ ១៥

រូបទី ៨៖ ការអភិវឌ្ឍន៍ផ្លូវថ្នល់នៅឃុំទួលគរគី (២០០៦-១១) ........ ១៧

រូបទី ៩៖ បញ្ហាដែលបានកំណត់ឃើញនៅក្នុងផ្នែកខ្លះនៃស្រុកព្រៃនប់ ........ ២០

រូបទី ១០. សំណើគម្រោងអាទិភាពនៅក្នុងឃុំសាកល្បងមណ្ឌលសីមា ........ ២៩

# សេចក្ដីផ្ដើម

## គោលការណ៍ណែនាំ និងឯកសារណែនាំដែលមានស្រាប់

នៅពេលថ្មីៗនេះ មានគោលការណ៍ណែនាំ និងឯកសារណែនាំមួយចំនួន ដែលទាក់ទងនឹងការកសាងផែនការអភិវឌ្ឍន៍ឃុំ។ ឯកសារទាំងនោះរួមមាន៖

- អនុក្រឹត្យស្តីពីនីតិវិធីកសាងផែនការប្រើប្រាស់ដីឃុំ/សង្កាត់ (ខែ ឧសភា ឆ្នាំ ២០០៩)
- ឯកសារណែនាំការអនុវត្តស្តីពីការកសាងផែនការប្រើប្រាស់ដីនៅថ្នាក់ឃុំ (CLUP) (២០០៩)[1] និង
- គោលការណ៍ណែនាំស្តីពីផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់(CDP) និងកម្មវិធីវិនិយោគឃុំ/សង្កាត់(CIP)ដែលរៀបចំដោយក្រុមការងារអន្តរក្រសួង (ខែកក្កដា ឆ្នាំ ២០០៧)

ដូច្នេះ ខ្លឹមសារនៅក្នុងឯកសារ CARP[2] នេះពុំមានគោលបំណងជំនួស ឬ ប្រឆាំងគោលការណ៍ណែនាំ និង នីតិវិធីដែលមានទាំងនោះឡើយ។

## គោលបំណងនៃឯកសារណែនាំនេះ

ឯកសារណែនាំនេះត្រូវបានបង្កើតឡើងដើម្បីបន្ថែមការពិចារណាអំពីការប្រែប្រួលអាកាសធាតុ នៅក្នុងដំណើរការកសាងផែនការសម្រាប់បំពេញបន្ថែមលើទិន្នន័យ/ការវិភាគដែលមានស្រាប់ ដើម្បីឲ្យការសម្រេច និងការវិនិយោគអាចធ្វើឡើង ដោយមានការយល់ដឹងអំពីនិទស្សន៍ប្រែប្រួលអាកាសធាតុ និង/ឬ ការរំពឹងទុកអំពីព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី។

ការពិចារណាទាំងនេះមានគោលដៅជួយប្រតិបត្តិករដើម្បីវាយតម្លៃ៖

- តើមានភស្តុតាងអំពីការប្រែប្រួលអាកាសធាតុនៅក្នុងទីតាំងណាមួយក្នុងតំបន់ឆ្នេរដែលកំពុងស្ថិតក្នុងការសិក្សាដែរឬទេ ដោយប្រើប្រាស់ទិន្នន័យដែលមានស្រាប់
- តើការប្រែប្រួលណាមួយទាំងនោះកំពុងមានឥទ្ធិពលខ្លាំងក្លាមកលើលក្ខខណ្ឌសេដ្ឋកិច្ច សង្គម និង/ឬ បរិស្ថាន នៅក្នុងតំបន់នោះឬទេ
- តើភាពងាយរងគ្រោះនៃតំបន់នោះ និងឬប្រជាពលរដ្ឋនៅចំពោះមុខការប្រែប្រួលអាកាសធាតុកំពុងប្រែប្រួលជាបន្តបន្ទាប់ដែរឬទេ? និង
- តើមានវិធានការបន្សាំដែលអាចរួមបញ្ចូលទៅក្នុងដំណើរការកសាងផែនការ ដើម្បីបង្កើនភាពធន់នៃតំបន់នោះ និង/ឬ ប្រជាពលរដ្ឋចំពោះការប្រែប្រួលអាកាសធាតុដែរឬទេ?

---

[1]រៀបចំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC)។ គាំទ្រដោយកម្មវិធីគ្រប់គ្រងធនធានធម្មជាតិ និងការចិញ្ចឹមជីវិត (NRM&L) ទទួលមូលនិធិពី Danida/DFID/NZAid។ ទាំងនេះគឺជាឯកសារណែនាំទូលំទូលាយសម្រាប់កសាងផែនការប្រើប្រាស់ដីនៅថ្នាក់ឃុំ (ដែលត្រូវគេស្គាល់ថាជា "សៀវភៅបៃតង")។

[2]សមាសភាគកសាងផែនការបន្សាំ និងភាពធន់ក្នុងតំបន់ឆ្នេរ (CARP) សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា

បន្ទាប់មកការវាយតម្លៃទាំងនេះ នឹងបង្កើតជាមូលដ្ឋានសម្រាប់ធាតុចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំនានា និងដំណើរការកសាងផែនការប្រើប្រាស់ដីទូលំទូលាយដែលពួកគេអាចមានការឯកភាពលើវិធានការបន្សាំ។ ដំណើរការ CLUP ត្រូវធ្វើឡើងវិញជារៀងរាល់៥ឆ្នាំម្តង (ដោយមានចក្ខុវិស័យ១០ ទៅ១៥ឆ្នាំ និងការពិនិត្យប្រចាំឆ្នាំ) ត្រូវធ្វើឡើងឲ្យចំពេលជាមួយផែនការអភិវឌ្ឍ (CDP) (ដែលមានអាណត្តិ៥ឆ្នាំផងដែរ) និងវដ្តនៃការរៀបចំកម្មវិធីវិនិយោគឃុំប្រចាំឆ្នាំ (CIP) ។

ការវាយតម្លៃនេះគ្មានគោលដៅប្រមូលទិន្នន័យបន្ថែមហួសពីអ្វីដែលបានប្រមូលផ្តុំមកស្រេចហើយនោះទេ[3] បើទោះជាអាចត្រូវការឲ្យមានសិក្សាបន្ថែមនៅដំណាក់កាលក្រោយ ដើម្បីកំណត់វិធានការបន្សាំសមស្រប ដែលអាចត្រូវការជាចាំបាច់ក៏ដោយ។ ឯកសារបណ្តុះបណ្តុះបណ្តាលងាយៗខ្លះ[4] ត្រូវបានអង្គការដទៃរៀបចំឡើង ដែលផ្តល់ជាសារវតាដ៏សំខាន់អំពីការប្រែប្រួលអាកាសធាតុ។

## ការកំណត់អត្តសញ្ញាណបញ្ហាប្រែប្រួលអាកាសធាតុនៅក្នុងដំណើរការកសាងផែនការឃុំ

មានមធ្យោបាយមួយចំនួនដែលអាចប្រើប្រាស់សម្រាប់កំណត់អត្តសញ្ញាណ និងដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនៅក្នុងដំណើរការជារួមនៃការកសាងផែនការឃុំ។ មធ្យោបាយទាំងនោះរួមមាន៖

- ផែនទីអំពីទីតាំងជាចំណាប់អារម្មណ៍នៅក្នុងខេត្ត៖ ផ្អែកលើបញ្ហាដែលបានកំណត់អត្តសញ្ញាណ និងរៀបចំជាផែនទីនៅថ្នាក់ខេត្ត។ ផែនទីនេះមានគោលដៅកំណត់អត្តសញ្ញាណកន្លែងនានាដែលត្រូវការឲ្យមានកិច្ចការពារជាពិសេស បើទោះបីមានមាត្រដ្ឋានតូចក៏ដោយ (១៖១០០.០០០ ឬ ១៖២៥០.០០០) ដែលមានន័យថាទីតាំងធំៗដែលបានដាក់បញ្ចូល។ ផែនទីអំពីទីតាំងជាចំណាប់អារម្មណ៍ដទៃទៀតដែលមានពីថ្នាក់ស្រុក និងឃុំក៏ត្រូវយកមកពិនិត្យផងដែរ។
- ផែនទីប្រើប្រាស់ដីពិស្តារ៖ ផែនទីនេះអាចកំណត់អត្តសញ្ញាណការប្រែប្រួលនានានៃការប្រើប្រាស់ដីដែលអាចទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដោយសារតែមាត្រដ្ឋាន (១៖១០.០០០ ដល់ ១៖៣០.០០០) មានទំហំធំគ្រប់គ្រាន់សម្រាប់កំណត់អំពីការប្រែប្រួលជាបន្តបន្ទាប់នូវដំណាំ សំណឹកតំបន់ឆ្នេរ និង/ឬដងទន្លេ។
- ផែនទីបញ្ហា៖ ដែលនៅលើផែនទីនោះគណៈកម្មការកសាងផែនការឃុំ និងថវិកា (PBC) និងបុគ្គលនានានៅក្នុងឃុំអាចកំណត់អត្តសញ្ញាណបញ្ហា មូលហេតុ និងដំណោះស្រាយនានា។
- សៀវភៅទិន្នន័យសម្រាប់ស្រុក ឃុំ និងភូមិ៖ កំណត់អត្តសញ្ញាណបញ្ហានានា ឬ តាមរយៈការប្រៀបធៀបព័ត៌មាននៅក្នុងសៀវភៅទិន្នន័យទាំងនោះជាបន្តបន្ទាប់ ដូចជា ការថយចុះនៃចំនួនប្រជាជន ការប្រែប្រួលចំនួនអ្នកប្រកបរបរកសិកម្ម និងទិន្នផល។
- ជាតុចូលពីការកសាងផែនការប្រើប្រាស់ដីតាមបែបផែននៃការចូលរួម (PLUP) ការវិភាគកសិ-ប្រព័ន្ធអេកូឡូស៊ីនៅថ្នាក់ឃុំ (CAEA) ឬ ដំណើរការផ្លូវការដទៃទៀត។

[3]ឃុំទាំងអស់បានផ្តល់ទិន្នន័យរួចមកហើយអំពីបញ្ហាដែលមានស្រាប់ និងដែលកំពុងមានឥទ្ធិពលមកលើតំបន់របស់ពួកគេ រួមជាមួយសំណើគម្រោងអាទិភាពដើម្បីដោះស្រាយបញ្ហាទាំងនោះ។

[4]ឯកសារបណ្តុះបណ្តាលសម្រាប់គ្រូអំពីការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ឆ្នេរ ដោយអង្គការសង្គ្រោះសត្វព្រៃកម្ពុជា គ្មានកាលបរិច្ឆេទ។

- ការអង្កេត និងការសិក្សាដទៃទៀត៖ មិនមែនជាផ្នែកមួយនៃដំណើរការ CLUP ដែលមានរយៈពេល ៥ឆ្នាំ បានផ្តួចផ្តើមជាដំណើរការតាមវិធានពីលើមកក្រោម (ដូចជា ការពិនិត្យរូបថតពីអាកាសទៅតាមពេលវេលា) ឬ ពីក្រោមមកលើ (របាយការណ៍របស់មន្រ្តី ឬនិង/ឬអ្នកភូមិអំពីព្រឹត្តិការណ៍គ្រោះមហន្តរាយ) នៃការកំណត់អត្តសញ្ញាណបញ្ហា។ រួមបញ្ចូលទីតាំងជាទីចំណាប់អារម្មណ៍នានានៅមូលដ្ឋាន។
- បទពិសោធន៍ និងចំណេះដឹងរបស់អ្នកភូមិអំពីអ្នកណាខ្លះបានរស់នៅក្នុងតំបន់នោះជាយូរមកហើយ និងអ្នកណាដែលបានដឹងអំពីការប្រែប្រួលសំណុំលក្ខណៈនៅក្នុងឃុំរបស់ខ្លួន សូម្បីតិចតួច។

ឃុំគួរតែប្រើប្រាស់ប្រភពព័ត៌មានដែលខ្លួនមាន នៅក្នុងការរៀបចំធាតុចេញដែលចាំបាច់ បន្ថែមលើធាតុចេញដែលផ្តល់ដោយ CARP។

**ដំណើរការសម្រាប់ប្រើប្រាស់គោលការណ៍ណែនាំនេះ**



# បរិបទនៃការកសាងផែនការ

| **លទ្ធផលរំពឹងទុក** |
|---|
| • ការពិនិត្យឡើងវិញផែនការ/គម្រោង/គោលនយោបាយដែលលើកស្នើឡើងនៅថ្នាក់ជាតិ ខេត្ត និង/ឬ ស្រុក ដែលអាចមានឥទ្ធិពលមកលើឃុំ |
| **វត្ថុមានទិន្នន័យ** |
| ផែនការថ្នាក់ខេត្ត និងស្រុក ដែលចែងពិស្តារអំពីគម្រោងដែលបានលើកឡើងបច្ចុប្បន្ននេះរួមជាមួយការកំណត់ថវិកា ដែលនឹងត្រូវអនុវត្តក្នុងពេល ១០ ឆ្នាំខាងមុខ។ |
| **ព័ត៌មាន** |
| ការកសាងផែនការអភិវឌ្ឍន៍ឃុំគួរតែធ្វើឡើងដោយមានចំណេះដឹងអំពីវត្ថុមានផែនការ គម្រោង និងគោលនយោបាយ ដែលរៀបចំឡើងនៅថ្នាក់ខ្ពស់ ដែលប្រសិនបើបានអនុវត្ត អាចមានឥទ្ធិពលធំៗមកលើមុខងាររបស់ឃុំ។ គម្រោងបែបនោះអាចរាប់បញ្ចូលហេដ្ឋារចនាសម្ព័ន្ធថ្មីៗ ដូចជា ផ្លូវថ្នល់ ទំនប់ និងបណ្តាញផ្គត់ផ្គង់ទឹក។ គោលនយោបាយក៏អាចមានការជម្រុញផងដែរ ដែលផ្តល់ការលើកទឹកចិត្តដល់ប្រជាជនដែលរស់នៅក្នុងតំបន់នេះ ដូចជា ជម្រុញពូជស្រូវថ្មីៗដែលលូតលាស់រហ័ស។ |
| **ដំណើរការ** |
| ក្នុងពេលពិនិត្យមើលផែនការ/គោលនយោបាយ និង/ឬ គម្រោងនានា ដែលស្ថាប័នថ្នាក់ជាតិ ខេត្តឬស្រុក បានផ្តល់មកឲ្យអ្នក ទន្ទឹមនឹងឯកសារដែលបានពីបុគ្គលិកថ្នាក់ខេត្ត/ស្រុក ត្រូវកំណត់អំពីៈ<br>• ផែនការ គម្រោងនិងគោលនយោបាយណាខ្លះដែលមានសក្តានុពលក្នុងការមានឥទ្ធិពលធំៗមកលើការកសាងផែនការអភិវឌ្ឍន៍នៅក្នុងឃុំរបស់អ្នក<br>• វាយតម្លៃថាតើការកសាងផែនការអភិវឌ្ឍន៍ឃុំរបស់អ្នកគួរតែកែសម្រួលបែបណា ដើម្បីដាក់បញ្ចូលសំណើពីថ្នាក់ខ្ពស់បែបនោះ។ |

# ការប្រើប្រាស់ទិន្នន័យស្ថិតិ

| លទ្ធផលរំពឹងទុក |
| --- |
| • ការពិនិត្យផ្នែកខ្លះៗនៃសៀវភៅទិន្នន័យឃុំសម្រាប់ឆ្នាំ ២០០៦-១២ ដើម្បីកំណត់រកបញ្ហាសម្រាប់ពិចារណារនៅក្នុងដំណើរការបណ្តុះបណ្តាល និងសម្រាប់ប្រមូលផ្តុំកម្រងទិន្នន័យទៅអនាគត |
| **វត្ថុមានទិន្នន័យ** |
| កម្រងទិន្នន័យឃុំសម្រាប់ដែលមានអត្ថាធិប្បាយបង្ហាញពី ៥២ចំណុចខុសៗគ្នានៅក្នុង ៤ ជំពូក (ប្រជាជន សេដ្ឋកិច្ច គ្រួសារ និងលទ្ធភាពចេញចូល) សម្រាប់ឆ្នាំ ២០០៦-១២។ |
| **ព័ត៌មាន** |
| សៀវភៅទិន្នន័យស្រុក ឃុំ និង ភូមិ មានសំណួរមួយចំនួន ពោលគឺ ការឆ្លើយតបទៅនឹងសំណួរទាំងនោះអាចប្រើប្រាស់សម្រាប់វាយតម្លៃភាពងាយរងគ្រោះនៃការប្រែប្រួលខុសៗគ្នានៃភាពងាយរងគ្រោះបច្ចុប្បន្ន[5] នៅចំពោះមុខការប្រែប្រួលអាកាសធាតុ ទោះបីវាជារចនាសម្ព័ន្ធ ប្រព័ន្ធ ឬ មនុស្សក៏ដោយ។ សៀវភៅទិន្នន័យទាំងនេះត្រូវបានផលិតឡើងជារៀងរាល់ឆ្នាំ (នៅខែធ្នូ) និងផ្សំដោយព័ត៌មានពិស្តារជាច្រើនអំពីជីវភាពនៅកម្រិតស្រុក ឃុំ និងភូមិ។ ក្នុងន័យនេះ វាអាចផ្តល់នូវមូលដ្ឋាននៃការវិភាគពីខាងក្រោមមកលើ អំពីថាតើការប្រែប្រួលអាកាសធាតុមានឥទ្ធិពលមកលើសហគមន៍ទាំងនោះឬយ៉ាងណា។<br><br>មានវិធីមួយចំនួន ដែលជាទូទៅគេអាចប្រើប្រាស់ទិន្នន័យទាំងនេះ៖<br><br>• ជាការប្រៀបធៀបឃុំ/ភូមិ ជាមួយឃុំ/ភូមិដទៃទៀត ឬ តួលេខមធ្យមសម្រាប់ស្រុកទាំងមូល ខេត្ត ឬ ប្រទេស។ តួលេខនេះអាចយកមកប្រើប្រាស់សម្រាប់ប្រៀបធៀបអត្រាកំណើន និងទិន្នន័យដែលទាក់ទងនឹងគុណផលដទៃទៀត (ដូចជា ស្តង់ដារជាតិសម្រាប់ការផ្តល់សេវា) ដើម្បីវាយតម្លៃថាតើកន្លែងណាមួយមានភាពខុសគ្នាពីកន្លែងដទៃទៀតដែរឬទេ។ ការធ្វើបែបនេះគួរតែអាចនាំទៅរកការសិក្សា និងពិភាក្សាអំពីមូលហេតុនៃភាពខុសគ្នាទាំងនោះ។ គេអាចធ្វើបែបនេះនៅពេលណាមួយ ឬ អាចជាបន្តបន្ទាប់ទៅតាមពេលវេលាខុសៗគ្នា។<br>• ការប្រៀបធៀបទិន្នន័យតាមពេលវេលាខុសៗគ្នានៅក្នុងឃុំ/ភូមិដដែល។ ឥឡូវនេះមានទិន្នន័យពិស្តាជាច្រើនចាប់ពីឆ្នាំ ២០០៦មក ដែលផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យមើលនិន្នាការ ឬ ភាពមិនប្រក្រតីដែលអាចបង្ហាញច្បាស់នៅក្នុងកម្រងទិន្នន័យ។<br><br>សំណៅតភ្ជាប់មួយអាចរកឃើញនៅក្នុងវេបសាយរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ http://ncdd.gov.kh/. |

[5]ភាពងាយរងគ្រោះត្រូវបានឲ្យនិយមន័យថាជា "លក្ខខណ្ឌនានាដែលកំណត់ដោយកត្តា ឬ ដំណើរការរូបវន្ត សង្គម សេដ្ឋកិច្ច និងបរិស្ថាន ដែលបង្កើនភាពងាយទទួលរងការប៉ះពាល់របស់សហគមន៍នៅចំពោះមុខសញ្ញាមហន្តរាយណាមួយ"។ ការវាយតម្លៃភាពងាយរងគ្រោះត្រូវបានឲ្យនិយមន័យថាជា "ការវាយតម្លៃអំពីកម្រិតនៃការបាត់បង់ ដោយសារតែធាតុផ្សំនៃហានិភ័យណាមួយ (ឬ ធាតុផ្សំមួយចំនួន) ដែលកើតចេញពីមុខសញ្ញាគ្រោះថ្នាក់ណាមួយនៅក្នុងកម្រិតធ្ងន់ធ្ងរណាមួយ"។

ទោះជាយ៉ាងណាក៏ដោយ ទិន្នន័យស្ថិតិត្រូវតែផ្តល់ទំនុកចិត្តអំពីសុក្រឹត្យភាព ដោយសារយើងត្រូវប្រើប្រាស់សម្រាប់វិភាគការប្រែប្រួល ឬសម្រាប់ប្រៀបធៀបរវាងកន្លែងនានា និងបន្ទាប់មកប្រើប្រាស់ជាធាតុចូលសម្រាប់ការកសាងផែនការទៅអនាគត។ ភាគច្រើននៃទិន្នន័យឃុំអាចជាការបូកសរុបទិន្នន័យថ្នាក់ភូមិនៅក្នុងឃុំនោះ។ ភាគច្រើននៃទិន្នន័យនៅថ្នាក់ស្រុក គឺជាការបូកសរុបទិន្នន័យនៅក្នុងឃុំទាំងអស់នៃស្រុកនោះ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលប្រមូលទិន្នន័យ ជាញឹកញាប់អាចមានការបកស្រាយអំពីអ្វីដែលត្រូវការចាំបាច់ ដែលជាញឹកញាប់អាចនាំឲ្យមានភាពមិនសុក្រឹត្យ។ នេះអាចមានន័យថា ទិន្នន័យពីមួយឆ្នាំ ទៅមួយឆ្នាំ និងពីកន្លែងមួយទៅកន្លែងមួយ មិនអាចប្រៀបធៀបគ្នាបានដោយងាយស្រួលឡើយ។ ការពង្រីកក្នុងពេលថ្មីៗនេះនូវចំនួនតួលេខមួយចំនួនដែលប្រមូលបាន បង្ហាញពីការលំបាកមួយសម្រាប់អ្នកដែលមានបំណងប្រៀបធៀបជំពូកថ្មីៗជាមួយ ជំពូកចាស់ៗ។

ដូច្នេះ នេះគឺជាលំហាត់មួយដែលត្រូវពិនិត្យមើលទិន្នន័យសរុប និងធានាថា វាឆ្លុះបញ្ចាំងស្ថានភាពពិតទៅតាមកម្រិតដែលអាចយល់បាន។ រាល់ភាពមិនប្រក្រតីឬភាពមិនសុក្រឹត្យអាចយកមកវិភាគនៅក្នុងពេលបណ្តុះបណ្តាល និងអាចប្រើប្រាស់ជាធាតុចូលផងដែរសម្រាប់កែលម្អប្រព័ន្ធប្រមូលទិន្នន័យសម្រាប់បណ្តាឆ្នាំខាងមុខ។ ទិន្នន័យខាងក្រោមនេះគួរតែត្រូវពិនិត្យឡើងវិញសម្រាប់ឃុំនីមួយៗ សម្រាប់ជាឧទាហរណ៍នៃតួលេខនានាដែលត្រូវការសម្រាប់ការសិក្សាជាបន្ថែម។ តួលេខទាំងនេះត្រូវបានកំណត់ឃើញ ដោយសារតែវាមិនមានលំនាំតាមនិន្នាការដែលរំពឹងទុក វាអាចគ្មានភាពទៀងទាត់ ឬ មិនឆ្លើយតបជាមួយទិន្នន័យដទៃទៀត ដែលប្រមូលបាន។

| | |
|---|---|
| ឃុំអូរឧកញ៉ាហេង | ឆ្នាំ ២០១០៖ ចំនួនត្រីចិញ្ចឹម ឆ្នាំ ២០០៩ ចំនួនផ្ទះដែលមានអគ្គិសនី។ ផ្លូវដី ឆ្នាំ ២០០៩ -១០. ចម្ងាយទៅមណ្ឌលសុខភាព ឆ្នាំ ២០១១។ |
| ឃុំព្រៃនប់ | ២០១១៖ គ្មានដីស្រែ។ អណ្តូងគ្មានរបាំងការពារ ២០១១។ ១២. ប្រភពទឹកគ្រប់ រដូវ។ ផ្លូវដី និងផ្លូវមិនមែនដី ឆ្នាំ ២០០៩ |
| ឃុំទួលទទឹង | ម៉ាស៊ីនកិនស្រូវចាប់ពីឆ្នាំ ២០១០មក។ ទឹកស្អាតគ្រប់រដូវ។ អណ្តូងគ្មានរបាំងការពារ។ ស្ពាន (ម៉ែត្រ) ឆ្នាំ ២០០៩តមក។ |
| ឃុំសាមគ្គី | ផ្ទះមានអគ្គិសនីឆ្នាំ ២០១១។ អណ្តូងទឹកស្អាត ឆ្នាំ ២០១០។ អណ្តូងគ្មានរបាំងការពារ ឆ្នាំ ២០១១។ ផ្លូវ(ពីកណ្តាលភូមិទៅផ្លូវជំជិតជាងគេ) ២០១១-១២ |
| ឃុំទឹកល្អក់ | មានដីស្រែ ២០១១។ ម៉ាស៊ីនកិនស្រូវពីឆ្នាំ ២០១០តមក។ ផ្លូវចូល(ពីកណ្តាលភូមិទៅផ្លូវជំជិតជាងគេ) ២០១១-១២។ |
| ឃុំទឹកថ្លា | ដីស្រែនិង% ប្រើប្រាស់ពីឆ្នាំ២០១០តមក។ ទូកម៉ាស៊ីនពីឆ្នាំ ២០១០តមក។ ប្រភពទឹកគ្រប់រដូវ។ ផ្លូវដី ២០១០។ ផ្លូវចូល(ពីកណ្តាលភូមិទៅផ្លូវជំជិតជាងគេ) ២០១១-១២ |
| ឃុំពាមក្រសោប | ចិញ្ចឹមត្រីពីឆ្នាំ ២០០៨មក។ អណ្តូងទឹកស្អាត ២០១១។ ផ្លូវ(មិនមែនដី និងផ្លូវដី) ឆ្នាំ២០០៨តមក។ ស្ពាន (ម៉ែត្រ) ២០០៨។ បំពង់លូដោះទឹក ២០០៨តមក។ |
| ឃុំទួលគរគី | អណ្តូងគ្មានរបាំងការពារ ២០១១។ ផ្លូវដី ២០១០-១១។ ស្ពាន ២០០៧តមក។ |

| **ដំណើរការ** |
|---|
| ការពិនិត្យតួលេខស្ថិតសម្រាប់ឃុំរបស់អ្នកសម្រាប់ឆ្នាំ ២០០៦-១២ និងកំណត់៖<br>• តើមានចំនួននីមួយៗដែលត្រូវពិនិត្យ និងពិចារណាឡើងវិញឬទេ និង<br>• តើជាទូទៅតួលេខស្ថិតិអធិប្បាយពីស្ថានភាពក្នុងឃុំអ្នកឬទេសម្រាប់បណ្តាឆ្នាំមួយចំនួន។ |

# ចំនួនប្រជាជន

<table>
<tr><td colspan="2">លទ្ធផលរំពឹងទុក</td></tr>
<tr><td colspan="2">ការយល់ដឹងអំពីការប្រែប្រួលចំនួនប្រជាជនក្នុងឃុំពីឆ្នាំ ២០០៦-១២ ពោលគឺ អំពីអត្រាកំណើន ផ្ទះសំបែង ចំណាកស្រុក យេនឌ័រ និងជនងាយរងគ្រោះ</td></tr>
<tr><td colspan="2">វត្ថុមានទិន្នន័យ</td></tr>
<tr><td colspan="2">កម្រងទិន្នន័យឃុំតាមអនឡាញ ចាត់ជាជំពូកដូចតទៅ (២០០៦-១២)</td></tr>
<tr><td>• ចំនួនប្រជាជន<br>• ចំនួនគ្រួសារ<br>• ចំនួនគ្រួសារមានស្ត្រីជាមេគ្រួសារ<br>• ចំនួនប្រជាជនក្នុងអាយុធ្វើការ (អាយុ ១៨-៦០)<br>• មនុស្សចាស់ គ្មានអ្នកមើលថៃ<br>• ជនរងគ្រោះពីគ្រោះធម្មជាតិ<br>• ជនពិការងាយរងគ្រោះ</td><td>• ចំណាកស្រុក៖ ស្នាក់នៅក្នុងឃុំជាអចិន្ត្រៃយ៍<br>• ចំណាកស្រុក៖ ចេញពីឃុំជាអចិន្ត្រៃយ៍<br>• ចំណាកស្រុកទៅរកការងារធ្វើក្រៅឃុំ<br>• ក្នុងនោះស្ត្រី<br>• ចំណាកស្រុក៖ ក្នុងឃុំជាបណ្តោះអាសន្ន</td></tr>
<tr><td colspan="2">ព័ត៌មាន</td></tr>
<tr><td colspan="2">"ចំនួនប្រជាជន"កំពុងស្ថិតក្នុងការពិនិត្យ ដើម្បីវាយតម្លៃពីកំណើនជាបន្តបន្ទាប់នៃតួលេខធៀបចំនួនប្រជាជន ដែលអាចប្រើប្រាស់ជាសូចនាករជំនួសអំពីភាពទាក់ទាញជារួមនៃតំបន់មួយចំពោះអ្នកចំណូលថ្មី។ ក្រាហ្វិកខាងក្រោមនេះ (រូបទី ១) បង្ហាញពីអត្រាកំណើនចំនួនប្រជាជន (អត្រាកំណើនជាមធ្យមប្រចាំឆ្នាំ ឬ AAGR) នៃឃុំសាកល្បងចំនួន ៨ ក្នុងរយៈពេល ៦ឆ្នាំ (៥ឆ្នាំសម្រាប់ឃុំមណ្ឌលសីម៉ា) ចាប់ពីឆ្នាំ ២០០៦ -១២។ តួលេខនេះប្រៀបធៀបជាមួយ AAGR នៅទីជនបទនៃខេត្តកោះកុង និងខេត្តព្រះសីហនុ រវាងអំឡុងពេលជំរឿនឆ្នាំ ១៩៩៨-២០០៨។ នេះមិនមែនមានគោលដៅប្រៀបធៀបជាក់លាក់ឡើយ។ ការប្រៀបធៀបនេះប្រើប្រាស់ទិន្នន័យដែលអាចរកបានដោយងាយស្រួល និងដែលអាចប្រើប្រាស់សម្រាប់ជូនដំណឹងដល់ប្រតិបត្តិករអំពីបញ្ហាដែលអាចកើតមាន ដែលអាចត្រូវសិក្សាឲ្យបានពិស្តារបន្ថែមទៀតដោយប្រើប្រាស់ទិន្នន័យដទៃទៀត។</td></tr>
</table>

**រូបទី ១. កំណើនចំនួនប្រជាជនក្នុងឃុំ និងទីជនបទក្នុងខេត្ត**




ក្នុងខេត្តព្រះសីហនុ តួលេខបង្ហាញច្បាស់ថា ឃុំព្រៃនប់ ទួលទទឹង និងអូរឧកញ៉ាហេង មានអត្រាកំណើនប្រជាជនកម្រិតខ្ពស់ ប្រហែលគ្នានឹងតួលេខមធ្យមតាមបណ្តាខេត្តនៅជនបទ។ ឃុំចំនួនពីរផ្សេងទៀត ទឹកល្អក់ និងទឹកថ្លា មានអត្រាខ្ពស់ និងសាមគ្គីមានអត្រាកំណើនអវិជ្ជមាន។ នៅកោះកុង ឃុំទួលគរគី មានអត្រាខ្ពស់ជាខ្លាំងធៀបនឹងតួលេខមធ្យម ចំណែកនៅពាមក្រសោប តួលេខនេះអវិជ្ជមាន។

អត្រាខុសគ្នាសម្រាប់ឃុំនីមួយៗ បានបង្ហាញពីសំណុំលក្ខណៈខុសគ្នាជាខ្លាំងដែលអាចមានឥទ្ធិពលមកលើភាពទាក់ទាញ ឬ សូម្បីតែរំខានចំពោះការតាំងទីលំនៅនៅក្នុងតំបន់នេះក៏ដោយ។ ប្រការសំខាន់គឺត្រូវយល់ពីមូលហេតុដែលនាំឲ្យមានភាពខុសគ្នាបែបនេះ។ ទិន្នន័យពិស្តារជាងនេះអាចជួយនៅក្នុងការស្វែងយល់បែបនេះ។

អត្រាកំណើនចំនួនប្រជាជនក៏អាចមានសារៈសំខាន់ផងដែរ នៅពេលពិចារណាអំពីភាពងាយរងគ្រោះទៅអនាគតនៃប្រជាជននៅចំពោះមុខហានិភ័យនៃការប្រែប្រួលអាកាសធាតុ។ ប្រជាជនដែលមានចំនួនកើនឡើង និងដែលកាន់តែងាយរងគ្រោះ អាចងាយរងការប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ប្រសិនបើពួកគេស្ថិតនៅក្នុងតំបន់ងាយជួបគ្រោះមហន្តរាយ ឬ រស់ក្នុងលក្ខខណ្ឌគ្រោះថ្នាក់។

**យេនឌ័រ និងជនងាយរងគ្រោះ**

ចំនួន ឬ សមាមាត្រនៃគ្រួសារដែលមានស្ត្រីជាមេគ្រួសារ ច្រើនតែអាចចាត់ទុកជាសូចនាករនៃភាពងាយរងគ្រោះជាពិសេស នៅពេលដែលគ្រោះមហន្តរាយវាយប្រហារតំបន់ណាមួយ។ ស្ត្រីដែលមានបណ្តាញគាំទ្រតូចជាង និងច្រើនតែមានកូនតូចៗ នឹងមានតម្រូវការជាពិសេសនៅក្នុងពេលដែលពួកគេអាចមានធនធានក្នុងកម្រិតកំណត់ដើម្បីទប់ទល់នឹងគ្រោះមហន្តរាយ។ ចំនួនជនពិការ ឬ មនុស្សចាស់ក៏ជាកត្តាដែលគួរតែពិនិត្យផងដែរ ដើម្បីវាយ

តម្លៃពីលទ្ធភាពធ្វើចរាចររបស់ប្រជាជន និងល្បឿនដែលពួកគេអាចប្រតិកម្មតបទៅនឹងព្រឹត្តិការណ៍កំណាច។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងករណីឃុំសាកល្បងចំនួន ៦ នៅស្រុកព្រៃនប់ ទិន្នន័យនេះមិនអាចស្តែងឲ្យឃើញច្បាស់លាស់ឡើយដូចមានបង្ហាញ(នៅក្នុងរូបទី ២)។ អត្រាគ្រួសារដែលមានស្ត្រីជាមេគ្រួសារនៅមណ្ឌលសីម៉ា (ក្នុងឃុំសាកល្បងចំនួន ២) មានប្រមាណ ៩% នៃមានស្ថិរភាពនៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ ក្នុងឃុំសាកល្បងចំនួន ៦នៅព្រៃនប់ តួលេខមធ្យមបច្ចុប្បន្នគឺប្រមាណ ១៣% ដោយមានភាពខុសគ្នាច្រើនទៅតាមពេលវេលា និងរវាងឃុំនានា។ មានតួលេខខ្ពស់ជាងនេះនៅឃុំព្រៃនប់ និងសាមគ្គី ក្នុងនោះភូមិខាងក្រោយមានគ្រួសារចំនួនមួយភាគបួនមានស្ត្រីជាមេគ្រួសារ។

**រូបទី ២. គ្រួសារដែលមានស្ត្រីជាមេគ្រួសារ (២០០៦-១២)**




ទំនាក់ទំនងរវាងចំនួនជនចំណាកស្រុក ក្នុងចំណោមស្ត្រី និងបុរស ដែលស្វែងរកការងារនៅក្រៅឃុំសាកល្បងព្រៃនប់បានបង្ហាញឲ្យឃើញច្បាស់លាស់ ទោះបីមិននៅក្នុងឃុំនានាក្នុងស្រុកមណ្ឌលសីម៉ាក៏ដោយ។ ចំនួនបុគ្គលដែលស្វែងរកការងារនៅក្នុងឃុំទាំងនេះបានកើនឡើងពី ៧៣៤នាក់ដល់ ១៧៦៩នាក់ក្នុងមួយឆ្នាំ (២០០៨-១២) ទោះបីចាប់ពីឆ្នាំ ២០១០មក ភាគច្រើននៃអ្នកទាំងនោះគឺជាបុរស (រូបទី ៣)ក៏ដោយ។ ជាការច្បាស់ណាស់ថា បុរសកាន់តែច្រើននឹងស្វែងរកការងារដោយទុកឲ្យស្ត្រីនៅមើលថែគ្រួសារ។ អ្វីៗទាំងអស់មានសមភាព នេះបង្ហាញពីកំនើនភាពងាយរងគ្រោះនៅចំពោះមុខគ្រោះមហន្តរាយធម្មជាតិ ដូចជា ព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី។

| រូបទី ៣. ការងារនៅក្រៅតំបន់នេះ (២០០៨-១២) |
|---|
|   |
| **ដំណើរការ** |
| ពិនិត្យទិន្នន័យដែលមានសម្រាប់ឃុំរបស់អ្នក និងឆ្លើយចំពោះសំណួរទាំងនេះ។ |
| **ចំនួនប្រជាជន** |
| • តើចំនួនប្រជាជននៅក្នុងឃុំរបស់អ្នក (២០០៦-១២) បានកើនឡើងយឺតៗ ឬ រហ័សជាងតួលេខមធ្យមក្នុងខេត្ត?<br>• តើអ្នកគិតថាអ្វីខ្លះជាមូលហេតុនៃភាពខុសគ្នានៃអត្រាកំណើននេះ?<br>• តើមានវិធីដើម្បីបញ្ចៀសការធ្វើចំណាកស្រុកចេញពីឃុំដែរឬទេ ជាពិសេសស្ត្រី? |
| **ការប្រែប្រួលអាកាសធាតុ** |
| • តើអ្នកគិតថាមានហេតុផលណាមួយដែលនាំឲ្យអត្រាកំណើនរបស់ប្រជាជនមានយឺត/លឿនដែរឬទេ ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ឬ ព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី? បើមាន តើហេតុផលអ្វីខ្លះ?<br>• តើព្រឹត្តិការណ៍អ្វីដែលបង្កឲ្យមាន "ជនរងគ្រោះពីគ្រោះមហន្តរាយធម្មជាតិ" ដូចមានតួលេខក្នុងស្ថិតិ? |

# សេដ្ឋកិច្ច

<table>
<tr><td colspan="2">លទ្ធផលរំពឹងទុក</td></tr>
<tr><td colspan="2">• ការយល់ដឹងអំពីរចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ឃុំ និងតើស្ថានភាពនេះបានប្រែប្រួលបែបណា ឬហេតុអ្វីប្រែប្រួលចាប់ពីឆ្នាំ ២០០៦-១២មក។</td></tr>
<tr><td colspan="2">វត្ថុមានទិន្នន័យ</td></tr>
<tr><td colspan="2">កម្រងទិន្នន័យឃុំដែលមានអនឡាញ សម្រាប់ជំពូកដូចតទៅ (២០០៦-១២)៖</td></tr>
<tr><td>• របរចំបង៖ ស្រូវ<br>• របរចំបង៖ នេសាទ<br>• របរចំបង៖ ក្រៅពីកសិកម្ម<br>• ទិន្នផលស្រូវវស្សា<br>• ទំហំដីស្រែ<br>• ទំហំដីស្រែ<br>• ទំហំស្រែដែលមានប្រព័ន្ធស្រោចស្រពនៅរដូវប្រាំង<br>• លទ្ធភាពទទួលបានទឹកស្រោចស្រព<br>• មានដីស្រែ<១ហ.ត<br>• គ្មានដីស្រែ<br>• ម៉ាស៊ីនកិនស្រូវ (ខ្នាតតូច មធ្យម ធំ)</td><td>• ចំនួនទូកម៉ាស៊ីនសរុប<br>• ចិញ្ចឹមត្រី<br>• ក្នុងនោះ ចិញ្ចឹមក្នុងស្រះ (អ្នកដទៃទៀតក្នុងបែរ)<br>• ស្រះត្រី<br>• ចិញ្ចឹមបង្គារ<br>• ស្រះបង្គារ<br>• ស្រះបង្គារ</td></tr>
<tr><td colspan="2">ព័ត៌មាន</td></tr>
<tr><td colspan="2">នៅទូទាំងពិភពលោក សមាមាត្រអ្នករស់នៅទីក្រុងបានកើនឡើងជាបន្តបន្ទាប់ ហើយឥឡូវមានច្រើនជាង ៥០%។ ដូចគ្នានេះដែរអាចនិយាយចំពោះមុខរបរ ក្នុងនោះសមាមាត្រតិចជាងដែលត្រូវការ និងដែលចង់ពាក់ព័ន្ធក្នុងសកម្មភាពនៅជនបទ។ ប្រទេសរបរចិញ្ចឹមជីវិតដែលបានអនុវត្តនឹងមានភាពខុសគ្នា អាស្រ័យតាមកត្តាជាច្រើន ដែលរួមទាំងការប្រែប្រួលអាកាសធាតុ។ តារាងខាងក្រោម (រូបទី ៤) បង្ហាញទម្រង់ខុសគ្នាជាខ្លាំងនៃការងារដែលជារបរចំបងសម្រាប់គ្រួសារនានាក្នុងឃុំចំនួន ២នៅក្នុងស្រុកតែមួយ។ ប្រតិបត្តិករអាចចង់ស្វែងយល់ពីមូលហេតុដែលសមាមាត្រគ្រួសារដែលពាក់ព័ន្ធក្នុងការនេសាទនៅពាមក្រសោបបានថយចុះ និងជំនួសដោយការងារផ្សេងទៀតក្នុងកសិកម្ម។ ចំនួនអ្នកដែលពាក់ព័ន្ធក្នុងការនេសាទនៅទួលគរគី ក៏ថយចុះផងដែរក្នុងអំឡុងពេលដូចគ្នា ប៉ុន្តែជំនួសដោយការធ្វើស្រែ។</td></tr>
</table>

**រូបទី ៤. ការប្រែប្រួលរបរចំបងប្រចាំគ្រួសារក្នុងស្រុកមណ្ឌលសីម៉ា (២០០៨-១០)**




ជាសំណាងអាក្រក់ ចាប់ពីឆ្នាំ ២០១១មក ទិន្នន័យនេះទាក់ទងនឹងបុគ្គល តែមិនមែនគ្រួសារឡើយ ដូច្នេះមិនងាយក្នុងការប្រៀបធៀបឡើយជាមួយទិន្នន័យថ្មីៗ។

**ដំណើរការ**

ពិនិត្យទិន្នន័យដែលមានសម្រាប់ឃុំរបស់អ្នក និងឆ្លើយសំណួរដូចតទៅ៖

**ចំនួនប្រជាជន**

- តើមុខរបរនៅក្នុងឃុំរបស់អ្នក (២០០៦-១២) នៅក្នុងក្រុមនីមួយៗ៖ ស្រូវ ត្រី និងមិនមែនកសិកម្ម បានកើន ឬថយចុះ ?
- ហេតុអ្វីអ្នកគិតថាមានការកើនឡើង/ថយចុះបែបនេះ ?
- តើមានសក្តានុពលដើម្បីបង្កើនផ្ទៃដី (ហ.ត/មុ២) ឬ រដូវ (សប្តាហ៍/ខែ) ដែលបែងចែកសម្រាប់ធ្វើស្រែ ឬចិញ្ចឹមបង្គាដែរឬទេ ?
- តើអ្នករំពឹងថានឹងមានការប្រែប្រួលសមាមាត្រប្រជាកសិករអ្នកនេសាទ និងផ្តល់សេវាដែរឬទេទៅអនាគត ? ហេតុអ្វី ?

**ការប្រែប្រួលអាកាសធាតុ**

- តើអ្នកគិតថាមានហេតុផលណាមួយខាងក្រោមនេះដែលធ្វើឲ្យប្រែប្រួលមុខរបរ ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ឬ ព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតីឬទេ ? ហេតុអ្វី ?
- តើអ្នករំពឹងថាការប្រែប្រួលអាកាសធាតុនិង/ឬព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតីមានឥទ្ធិពលមកលើមុខរបរទៅអនាគតដែរឬទេ ?

# ផ្ទះសំបែង និងសេវានានា

<table>
<tr><td colspan="2">លទ្ធផលរំពឹងទុក</td></tr>
<tr><td colspan="2">• ការយល់ដឹងអំពីការប្រែប្រួលនៃគុណភាពផ្ទះសំបែង និងការទទួលបានសេវានានា និងតើមានការប្រែប្រួលបែបណា ឬហេតុអ្វីមានការប្រែប្រួលពី ២០១៦-១២។</td></tr>
<tr><td colspan="2">វត្ថុមានទិន្នន័យ</td></tr>
<tr><td colspan="2">កម្រងទិន្នន័យឃុំមាននៅអនឡាញ សម្រាប់ជំពូកដូចតទៅ (២០០៦-១២)៖</td></tr>
<tr><td>• ផ្ទះសំបែង៖ សរុប<br>• ផ្ទះសំបែង៖ ដំបូលស្លឹក<br>• ផ្ទះសំបែង៖ មានអគ្គិសនី<br>• រស់នៅក្នុងទីធ្លាសាធារណៈ</td><td>• បញ្ចូលអាគុយ<br>• ទឹកអណ្តូងស្អាត (ស្នប់ ចម្រុះ អណ្តូងលូ)<br>• ក្នុងនោះមិនអាចប្រើបាននៅរដូវប្រាំង<br>• អណ្តូង (ស្នប់ ចម្រុះ លូ) ត្រូវការជួសជុល<br>• អណ្តូងគ្មានរបាំងការពារ<br>• ក្នុងនោះមិនអាចប្រើបាននៅរដូវប្រាំង<br>• ប្រភព>១៥០ម ពីផ្ទះ<br>• ទឹកមានសុវត្ថិភាពនៅរដូវប្រាំង (ស្នប់ ចម្រុះ)<br>• គ្មានសុវត្ថិភាពនៅរដូវប្រាំង(អណ្តូងលូ ជីក ស្រះ ទន្លេ)</td></tr>
<tr><td colspan="2">ព័ត៌មាន</td></tr>
<tr><td colspan="2">គុណភាពផ្ទះសំបែង<br>ក្រាហ្វិកខាងក្រោមនេះ(រូបទី ៥) បង្ហាញពិស្តារពីចំនួនផ្ទះដែលមានដំបូលស្លឹកនៅក្នុងឃុំទាំង ៦នៅព្រៃនប់។ មេឃុំអាចប្រៀបធៀបទិន្នន័យរវាងតំបន់នានា ជាតួលេខជំនួសសម្រាប់វឌ្ឍនភាពនៃការអភិវឌ្ឍ និងកម្រិតប្រាក់ចំណូលក្នុងឃុំរបស់ពួកគេ ឬ ភាពងាយរងគ្រោះដែលអាចមាននៅចំពោះមុខគ្រោះមហន្តរាយ ដូចជា ខ្យល់ព្យុះ/ស៊ីក្លូន។ ក្នុងឧទាហរណ៍នេះ ឃុំទាំងអស់មានការថយចុះជាខ្លាំងនៃភាពងាយរងគ្រោះរបស់ពួកគេនៅក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ ដោយប្តូរទៅដំបូលស័ង្កសី/ហ្វីប្រូស៊ីម៉ង់។</td></tr>
</table>

រូបទី ៥. ផ្ទះដែលមានដំបូលស្លឹកនៅស្រុកព្រៃនប់ (%នៃចំនួនសរុប)




## អគ្គិសនី

ដូចគ្នានេះដែរ ទិន្នន័យអំពីអគ្គិសនីអាចប្រើប្រាស់ជាតួលេខជំនួសសម្រាប់វឌ្ឍនភាពនៃការអភិវឌ្ឍ។ ការប្រៀបធៀបទិន្នន័យសម្រាប់ឃុំសាកល្បងក្នុងព្រៃនប់ និងមណ្ឌលសីម៉ា បង្ហាញថា ភាគរយនៃចំនួនផ្ទះដែលមានអគ្គិសនីបានកើនឡើងក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ ប៉ុន្តែតាមអត្រាលឿន(ធៀបនឹងតួលេខគោល)នៅព្រៃនប់(រូបទី ៦)។

## ការទទួលបានទឹកស្អាត

ទិន្នន័យខ្លះពិតជាបានបង្ហាញភ្លាមៗថា អាចមានបញ្ហាដែលត្រូវដោះស្រាយ។ នៅក្នុងក្រាហ្វិក(រូបទី ៧)ខាងក្រោម ការទទួលបានទឹកស្អាត និងទឹកមិនស្អាតមានបង្ហាញសម្រាប់គ្រួសារនៅក្នុងឃុំសាកល្បងចំនួន២ ក្នុងស្រុកមណ្ឌលសីម៉ា។ ទិន្នន័យនេះបង្ហាញថា ក្នុងឃុំពាមក្រសោប ការទទួលបានទឹកស្អាតបានកែលម្អនៅក្នុងឆ្នាំ ២០០៨-១០ ចំណែកនិន្នាការផ្ទុយពីនេះទំនងជាករណីសម្រាប់ឃុំទួលគរគីផងដែរ។ ជាការល្អឃុំទាំងពីរគួរតែមានទំនាក់ទំនងគ្នាដើម្បីពិនិត្យមើលតើកត្តាអ្វីខ្លះបានធ្វើឲ្យប្រែប្រួលក្នុងរយៈពេល ២ឆ្នាំ ដែលនាំឲ្យមានភាពខុសគ្នាបែបនេះ។ ជាសំណាងមិនល្អ ទិន្នន័យនេះមិនទំនងជាមានសម្រាប់ឆ្នាំ ២០១១តមកទេ។

រូបទី ៦. ផ្ទះដែលមានអគ្គិសនីនៅព្រៃនប់ និងមណ្ឌលសីម៉ា (២០០៨-១២)




រូបទី ៧. វេជ្ជប្រាំង. ការទទួលបានទឹកស្អាត នៅស្រុកមណ្ឌលសីម៉ា




ការផ្ដល់ទឹកស្អាតទៅអនាគតនឹងធ្វើឡើងតាមប្រព័ន្ធចែកចាយកណ្ដាលមួយជាងតាមរយៈអណ្ដូងដាច់ដោយឡែកពីគ្នា ដោយសារការធ្វើបែបនេះនឹងផ្ដល់សន្តិសុខជៀសផុតពីការបំពុល និងវត្តមានតាមរដូវ។ បច្ចុប្បន្នមានទិន្នន័យអំពីទឹកស្អាត ជាចំនួនអណ្ដូង និងតើអណ្ដូងទាំងនេះប៉ុន្មានដែលមិនអាចប្រើប្រាស់បាននៅរដូវប្រាំង។ ទោះជាយ៉ាងណាក្ដី ទិន្នន័យនេះមិនទៀងទាត់ទាល់តែសោះ និងទំនងជាលែងមានចាប់តាំងពីឆ្នាំ ២០១១តមក។

| **ការគ្រប់គ្រងសំណល់** |
|---|
| ទោះបីជាញឹកញាប់មិនត្រូវបានចាត់ជាអាទិភាពខ្ពស់ក៏ដោយ ការចោលសំណលរឹងមិនត្រឹមត្រូវអាចបង្កជាបញ្ហាខាងសុខភាពដោយសារវាផ្តល់ជាកន្លែងបង្ករោគ ការធ្វើឲ្យក្រខ្វក់ប្រភពទឹក និងស្ទះផ្លូវដោះទឹក។ ចំណុចនេះបានក្លាយជាបញ្ហាចំបងមួយនៅពេលចោលសំណលរឹងតាមទីកន្លែងដែលជន់លិច និងករណីកំណើនកំពស់ទឹកសមុទ្រ។ |
| **ដំណើរការ** |
| ពិនិត្យមើលទិន្នន័យដែលមានសម្រាប់ឃុំរបស់អ្នក និងឆ្លើយចំពោះសំណួរដូចតទៅៈ |
| **ផ្ទះសំបែង** |
| • ប្រៀបធៀបការប្រែប្រួលចំនួនប្រជាជននិងផ្ទះសំបែងក្នុងឃុំរបស់អ្នក (២០០៦-១២)។ តើវាប្រែប្រួលតាមអត្រាប្រហែលគ្នា ឬ ឥឡូវមានភាពខ្វះខាតផ្ទះសំបែង ឬ អតិរេកផ្ទះសំបែង?<br>• តើជាទូទៅផ្ទះសំបែងមានគុណភាពល្អជាងមុនដែរឬទេ គិតចាប់ពីឆ្នាំ ២០០៦មក? |
| **សេវានានា** |
| • តើការផ្គត់ផ្គង់អគ្គិសនីអាចទុកចិត្តបានឬទេ ឬតើប្រជាជននៅតែពឹងផ្អែកលើអាគុយ/ម៉ាស៊ីនភ្លើងឬទេ នៅពេលដែលដាច់ភ្លើងអគ្គិសនី?<br>• តើមានប្រភពផ្គត់ផ្គង់ទឹករួមធំៗឬទេ ជាពិសេសសម្រាប់រដូវប្រាំង? សូមបញ្ជាក់លើផែនទី និងអធិប្បាយអំពីសម្បទាដែលមាន (បំពង់ទឹក អណ្តូង អាង បឹង)។<br>• តំបន់ណាខ្លះទំនងជាមានបញ្ហាផ្គត់ផ្គង់ទឹក (គុណភាព បរិមាណ) ពិសេសនៅរដូវប្រាំង? សូមដៅលើផែនទី។<br>• តើមានសក្តានុពលដើម្បីបង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹករួមដែលអាចផ្តល់ទឹកដល់ឃុំទាំងមូលដែរឬទេ?<br>• តើមានទីតាំងសម្រាប់ទុកដាក់សំណល់រឹងក្នុងឃុំឬទេ? បើគ្មានទេ តើប្រជាជនចោលសំណល់នៅទីណា? បើមាន តើទីតាំងនោះស្ថិតក្នុងការគ្រប់គ្រងឬទេ? |
| **ការប្រែប្រួលអាកាសធាតុ** |
| • នៅពេលមានការកែលម្អផ្ទះសំបែង ឬផ្ទះសង់ថ្មី តើម្ចាស់/អ្នកសង់គិតបញ្ចូលអំពីការប្រែប្រួលអាកាសធាតុឬទេ? បើគិត សូមចុះចំណុចនានាដែលបានគិតឃើញ ដូចជាៈ<br>    • សង់ផ្ទះលើជន្ទល់ ឬ លើកគ្រឹះខ្ពស់<br>    • បំពាក់ទរ និងប្រព័ន្ធត្រងទឹកភ្លៀង<br>• តើអគារនានាប្រើប្រាស់ថាមពលកកើតឡើងវិញឬទេ? ដូចជា បន្ទះទទួលពន្លឺព្រះអាទិត្យ ឬ ថាមពលខ្យល់។<br>• តើអគារសាធារណៈត្រូវបានសាងសង់ដោយគិតគូរអំពីដីគ្មានស្ថិរភាព នៅក្នុងតំបន់ទំនាបឬទេ (ដូចជា តាមរយៈការសង់គ្រឹះឲ្យមាំ ឬ កាត់បន្ថយទម្ងន់នៃសំណង់)?<br>• តើទឹកស្អាតសម្រាប់ប្រើប្រាស់នៅរដូវប្រាំងកាន់តែសំបូរ ឬខ្សត់ជាងមុន (ចំនួន គុណភាព) ក្នុងឆ្នាំកន្លងទៅថ្មីៗនេះ? បើទឹកកាន់តែខ្សត់ តើនេះដោយការការប្រែប្រួលអាកាសធាតុឬទេ ឬ ដោយសារកំណើនចំនួនប្រជាជន ឬ កំណើនតម្រូវការទឹក? |

# ការចេញចូល

**លទ្ធផលរំពឹងទុក**

- ការយល់ដឹងអំពីលទ្ធភាពចេញចូលក្នុងឃុំនេះបានប្រែប្រួលបែបណា ចាប់ពីឆ្នាំ ២០០៦-១២ កន្លងមក

**វត្ថុមានទិន្នន័យ**

កម្រងទិន្នន័យឃុំតាមអនឡាញ ក្នុងជំពូកដូចខាងក្រោម (២០០៦-១២)

| | |
|---|---|
| • ផ្លូវថ្នល់ មិនមែនផ្លូវដី<br>• ផ្លូវដី<br>• ស្ពាន<br>• ស្ពាន<br>• បំពង់លូ | • ផ្លូវច្រកចូល<br>• ចម្ងាយទៅសាលារៀនជិតជាងគេ<br>• ចម្ងាយទៅផ្សារ<br>• ចម្ងាយទៅមណ្ឌលសុខភាព |

**ព័ត៌មាន**

កំណែលម្អលទ្ធភាពចេញចូលអាចបង្ហាញតាមរយៈប្រវែង និងគុណភាពផ្លូវថ្នល់នៅក្នុងឃុំ។ ដូចបង្ហាញ (រូបទី ៨) សម្រាប់ទួលគរគី គេអាចមើលឃើញថា ប្រវែងផ្លូវថ្នាល់ (ម) បានកើនឡើង (២០០៦-១១) ក៏ដូចជាផ្លូវមិនមែនដីផងដែរ។ ព័ត៌មានបែបនេះអាចរួមបញ្ចូលទាំង ប្រវែង/ចំនួនស្ពាន និងលូដោះទឹកផងដែរ។ ក្នុងតួលេខ គេអាចឃើញថា ប្រវែងផ្លូវដីមួយចំនួនត្រូវបានប្រែក្លាយជាផ្លូវមិនមែនដីនៅក្នុងឆ្នាំ ២០០៨។

**រូបទី ៨៖ ការអភិវឌ្ឍន៍ផ្លូវថ្នល់នៅឃុំទួលគរគី (២០០៦-១១)**



| |
|---|
| ការកែលម្អលទ្ធភាពចេញចូល ក៏ឆ្លុះបញ្ចាំងផងដែរពីការអភិវឌ្ឍឃុំជាទូទៅ ដូច្នេះកាត់បន្ថយចម្ងាយទៅកាន់សម្បទានានា ដូចជា ផ្សារ មណ្ឌលសុខភាព និងសាលារៀន។ បច្ចុប្បន្ននេះ លទ្ធភាពទៅកាន់មណ្ឌលបែបនេះមានភាពខុសគ្នាជាខ្លាំងរវាងឃុំនានា។ ចម្ងាយសម្រាប់ឃុំទាំង ៨ ទៅសាលារៀនមានពី០,៣៨-១,៦៣គម, ផ្សារ ៦,៥-១៩,៥គម និងទៅមណ្ឌលសុខភាព៖ ២,៥-២២គម។<br><br>កំណែលម្អលទ្ធភាពចេញចូលកើតមានតាមរយៈ"គម្រោង" ដែលក៏បង្ហាញផងដែរថា រដ្ឋាភិបាល និងប្រជាជនដែលរស់នៅក្នុងឃុំមានការប្ដេជ្ញាចំពោះតំបន់នោះទៅអនាគត។ តំបន់នានាដែលមានសក្ដានុពលតិចតួច និងការគាំទ្រទំនងជាមានតែកន្លែងជិតទីរួមស្រុក/ខេត្តដែលមានស្រាប់ និងផ្លូវមេ ដែលទំនងជាទទួលបានគម្រោងនិងការគាំទ្រច្រើនជាងទីប្រជុំជនដែលនៅឆ្ងាយ។<br><br>ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ វិស្វករទំនងជាមាននិន្នាការយោងទៅកំណើនកំពស់ទឹកសមុទ្រនិងគូសបញ្ជាក់ពីកម្រិតកំពស់ខ្ពស់ជាងមុនសម្រាប់ផ្លូវថ្នល់/សាលារៀន ដើម្បីដោះស្រាយបញ្ហានេះ។ ទោះជាយ៉ាងណាក៏ដោយ ការបង្កើនកំពស់ផ្លូវថ្នល់និង/ឬអគារច្រើនតែមានឥទ្ធិពលអវិជ្ជមានមកលើកន្លែងផ្សេង លើកលែងតែបានពិចារណាពេញលេញក្នុងដំណាក់កាលផែនការនិងអនុវត្ត។<br>ការបង្កើនកំពស់ផ្លូវត្រូវតែពិចារណាស្របជាមួយការសង់លូដោះទឹក ដើម្បីធានាថាទឹកជំនន់អាចដោះពីតំបន់នោះក្រោយមានភ្លៀងធ្លាក់ និងមិនស្ថិតនៅបន្តបង្កឲ្យមានជំនន់រយៈពេលវែង និងជំនន់កាន់តែអាក្រក់នោះឡើយ។ ការបង្កើនកំពស់ថ្នល់គួរពិចារណាត្រង់ផ្លូវកែងជាមួយផ្លូវដទៃដែលអាចមិនបានបង្កើនកំពស់ លទ្ធភាពក្នុងការរស់នៅតាមតំបន់នោះ (ដែលច្រើនតែទាបជាងកម្រិតកំពស់ដែលកំណត់ថ្មី) តាមដងផ្លូវ និងសម្រាប់ស្ពាននៅតាមដងផ្លូវនោះ អាចត្រូវចំណាយច្រើនដើម្បីបង្កើនកំពស់។<br><br>ការបង្កើនកំពស់អគារដោយចាក់ដីបំពេញអាចបង្កើតឲ្យមានកន្លែងដក់ទឹក និងជំនន់នៅកន្លែងទាបក្នុងទីជិតខាង ដូច្នេះត្រូវពិចារណាអំពីប្រព័ន្ធលូដោះទឹកមុននឹងធ្វើបែបនោះ។ វត្តមានកន្លែងដក់ទឹកអាចបង្កហានិភ័យចំពោះសុខភាពដោយសារតែទឹកដក់ និង/ឬបង្កើនជម្រកមូស។ |
| **ដំណើរការ** |
| ការពិនិត្យមើលទិន្នន័យដែលមានសម្រាប់ឃុំរបស់អ្នក និងអនុវត្តសកម្មភាពដូចតទៅ៖ |
| **ការចេញចូល** |
| • គូសផ្លូវចូលចំបងៗពីភូមិនីមួយៗក្នុងឃុំ ទៅកាន់ផ្លូវធំជិតជាងគេបំផុត(ជាតិ ខេត្ត ស្រុក) នៅក្នុងឬនៅក្រៅឃុំ<br>• កំណត់ទីតាំងសាលាបឋមសិក្សា មណ្ឌលសុខភាព ឬ ផ្សារនៅក្នុងឃុំនៅលើផែនទី (ឬទីតាំងជិតជាងគេបំផុត ប្រសិនបើស្ថិតនៅក្រៅឃុំរបស់អ្នក)<br>• ប្រសិនបើអ្នកចង់លក់ ឬ ទិញទំនិញ តើអ្នកទៅផ្សារនេះឬទៅកន្លែងផ្សេង? បើទៅកន្លែងផ្សេង តើនៅទីណា និងនៅចម្ងាយប៉ុន្មាន (គ.ម ឬ នាទី)<br>• សូមបញ្ជាក់លើផែនទីអំពីផ្លូវថ្មី/កែលម្អ (ផ្លូវដី ឬមិនមែនដី) ដែលអាចសម្រួលដល់ការចេញចូលរបស់ប្រជាជន<br>• សម្រាប់សហគមន៍ដែលមានទឹកប្រើប្រាស់ សូមកំណត់រកកំពង់ទឹកដែលមានស្រាប់។ សូមបញ្ជាក់នៅលើ |

| |
|---|
| ផែនទី នូវរាល់កំពង់ទឹកដែលមានផែថ្មី/កែលម្អ ដែលអាចសម្រួលការចេញចូលរបស់ប្រជាជន<br>ផ្អែកលើចំណុចខាងលើ៖<br>• តើការចេញចូលនៅក្នុងឃុំនេះបានកើនឡើងឬទេចាប់ពីឆ្នាំ ២០០៦មក?<br>• តើអាចកែលម្អលទ្ធភាពចេញចូលបានបន្ថែមទៀតឬទេ?បើអាច តើដោយរបៀបណា?<br>• ក្នុងរូបទី ៧ តើអ្នកអាចរកឃើញភាពមិនប្រក្រតីនៃទិន្នន័យដែលគួរតែពិនិត្យបន្ថែមឬទេ? |
| **ការប្រែប្រួលអាកាសធាតុ** |
| • សូមកំណត់រកទីតាំងនៅលើផ្លូវនានាដែលលិចទឹកជាទៀងទាត់<br>• សូមកំណត់រកទីតាំងនៅលើផ្លូវ/ស្ពាន/លំ ដែលអាចហូរច្រោះ<br>• សូមកំណត់រកទីតាំងទំនប់និងគូសបញ្ជាក់តំបន់នានា (ដែលរួមទាំង ឧបករណ៍គ្រប់គ្រងទឹក)ដែលត្រូវកែលម្អ<br>• ប្រសើនបើឃុំនេះនឹងជួបប្រឈមកំណើនកំពស់ទឹកសមុទ្រ ១០០ស.ម (យោងទៅផែនទីសណ្ឋានដី) តើផ្លូវណាខ្លះនឹងប៉ះពាល់? តើឃុំទាំងមូលនឹងនៅតែអាចចេញចូលមកផ្លូវធំ(ជាតិ/ខេត្ត/ស្រុក)បានដែរឬទេ?<br>• តើសំណើគម្រោងផ្លូវ/ស្ពាន/បំពង់លូរបស់អ្នក រួមបញ្ចូលការលៃទុកសម្រាប់ករណីប្រែប្រួលអាកាសធាតុ ឬព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតីដែលឬទេ ទាក់ទងនឹង៖<br>    • កំណើនកំពស់ទឹកសមុទ្រ<br>    • កម្រិតប្រៃ (កាត់បន្ថយការរងឥទ្ធិពល ឬ បង្កើនកិច្ចការពារលោហៈ)<br>    • កំដៅ (សម្ភារៈ ជាពិសេស ផ្លូវក្រាលកៅស៊ូ)<br>    • ការគិតគូរអំពីដីដែលគ្មានស្ថិរភាព និងងាយបាក់ស្រុត នៅក្នុងតំបន់ទំនាប (ដូចជា ការបុកគ្រឹះ)<br>    • ប្រសិនបើសំណើផ្លូវថ្នល់ត្រូវបង្កើនកំពស់ថែមទៀត តើមានការពិចារណាផលប៉ះពាល់នៃការបន្ថែមកំពស់ដល់ផ្លូវថ្នល់មកលើប្រព័ន្ធលូ ជាពិសេស លទ្ធភាពស្តុកទឹកជំនន់នៅក្រោយមានភ្លៀងធ្លាក់ខ្លាំងឬទេ?<br>    • ប្រសិនបើមានសំណើសាងសង់រចនាសម្ព័ន្ធណាមួយ ដូចជា ទំនប់ ឬ ផែនៅកំពង់ទឹក តើសំណើទាំងនោះមានរួមបញ្ចូលការបម្រុងទុកសម្រាប់ការប្រែប្រួលអាកាសធាតុឬទេ? (ដូចជា កំណើនកំពស់ទឹកសមុទ្រ ព្យុះរលក សកម្មភាពទឹករលក ខ្យល់ព្យុះស៊ីក្លូន)<br>    • ប្រសិនបើមានសំណើសាងសង់រចនាសម្ព័ន្ធណាមួយ ដូចជា ទំនប់ ឬ ផែននៅកំពង់ទឹក តើសំណើទាំងនោះមានបម្រុងទុកករណីដីគ្មានស្ថិរភាព និងងាយបាក់ស្រុតក្នុងតំបន់ទំនាបឬទេ? (ដូចជា ការបុកគ្រឹះ) |

# បញ្ហាដែលបានកំណត់ឃើញ

| លទ្ធផលរំពឹងទុក |
|---|
| • ការពិនិត្យមើលបញ្ហាដែលបានកំណត់ឃើញពីមុនមក និងបានកំណត់ក្នុងផែនទីឃុំ និងដែលមានឥទ្ធិពលមកលើការរស់នៅ និងលក្ខខណ្ឌការងារនៅក្នុងតំបន់នេះ |
| **វត្ថុមានទិន្នន័យ** |
| ផែនទីដែល CARP ផ្តល់ឲ្យ ដែលនៅលើផែនទីនោះឃុំនីមួយៗបានបន្ថែមបញ្ហានានាដែលបានកំណត់ឃើញ |
| **ព័ត៌មាន** |
| រួមជាមួយគម្រោង CARP កាលពីមុន តំណាងឃុំបានកំណត់ឃើញ និងដៅលើផែនទីនូវទីតាំងដែលមានបញ្ហាចំបងៗ នៅក្នុងកន្លែងរបស់ពួកគេ ដែលមានឥទ្ធិពលមកលើការលក្ខខណ្ឌរស់នៅនិងធ្វើការ។ បញ្ហាទាំងនេះរួមបញ្ចូលព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី ដូចជា ខ្យល់ព្យុះ និងទឹកជំនន់ ក៏ដូចជា បញ្ហាដែលអាចទាក់ទងនឹងការប្រែប្រួលអាកាសធាតុផងដែរ ដែលរួមទាំង ទិន្នផលស្រូវទាប ផលប៉ះពាល់នៃសត្វចង្រៃ និងវត្ថុមានទឹកក្នុងកម្រិតកំណត់។<br><br>ឧទាហរណ៍ដែលមានផ្តល់ខាងក្រោមនេះ (**រូបទី ៩**) បានមកពីភាគខាងត្បូងនៃស្រុកព្រៃនប់។ បញ្ហាដែលបានគូសបញ្ជាក់អំពីមូលដ្ឋាននៃការប្រើប្រាស់ដី បានផ្តល់លើទីកន្លែងនានាដែលតំណាងនានាមកពីឃុំសាកល្បងបានកំណត់អត្តសញ្ញាណកង្វះទឹកសម្រាប់ផ្គត់ផ្គង់ ទិន្នផលស្រូវទាប និងការលេចឡើងនៃសត្វចង្រៃ។<br><br>**រូបទី ៩៖ បញ្ហាដែលបានកំណត់ឃើញនៅក្នុងផ្នែកខ្លះនៃស្រុកព្រៃនប់**<br><br> |

| **ដំណើរការ** |
| --- |
| ពិនិត្យផែនទីដែលបានរៀបចំពីមុនមកសម្រាប់ឃុំរបស់អ្នក និង៖<br>• ពិចារណាថាតើអ្នកចង់ធ្វើការកែប្រែណាមួយចំពោះព័ត៌មានដែលបានផ្តល់រួចហើយដែរឬទេ<br>• ចូរបន្ថែមបញ្ហានានាដែលអ្នកអាចកំណត់ឃើញ ដែលជាលទ្ធផលនៃការបណ្តុះបណ្តាលក្នុងថ្ងៃនេះ៖<br>**សំគាល់៖ គម្រោងដែលកំណត់ឃើញដើម្បីដោះស្រាយបញ្ហាទាំងនេះមិនគួរបន្ថែមនៅក្នុងដំណាក់កាលនេះទេ** |

# ការកសាងផែនការប្រើប្រាស់ដី និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

| **លទ្ធផលរំពឹងទុក** |
| --- |
| • ការយល់ដឹងអំពីថាតើការប្រែប្រួលអាកាសធាតុអាចតម្រូវឲ្យឃុំបន្សាំទៅនឹងការលះទេសៈដែលប្រែប្រួលឬទេ |
| **វត្ថុមានទិន្នន័យ** |
| ផែនដីដែល CARP ផ្តល់ឲ្យ ដែលនៅលើផែនទីនោះមានការកំណត់អំពីសណ្ឋានដី។ |
| **ព័ត៌មាន** |
| **សន្មតថាមានការប្រែប្រួលអាកាសធាតុនៅកម្ពុជា**<br>នៅពេលថ្មីៗនេះ ADB បានរាយការណ៍ថា[6] "ភាពងាយរងគ្រោះកម្រិតខ្ពស់របស់កម្ពុជាចំពោះការប្រែប្រួលអាកាសធាតុជាប់ទាក់ទងនឹងកម្រិតទាបនៃសមត្ថភាពបន្សាំ និងការពឹងផ្អែកជាខ្លាំងលើវិស័យដែលងាយប្រែប្រួលដោយសារតែអាកាសធាតុ ដូចជា ធនធានទឹក និងកសិកម្ម។ ឧទា. ជំនន់នៅឆ្នាំ ២០១១ បានបង្កការខូចខាតប្រមាណ ៤៥១ លានដុល្លាអាមេរិក និងការបាត់បង់១៧៤លានដុល្លា។ ការវិភាគលើម៉ូដែលចរន្តទូទៅចំនួន ១៤ បង្ហាញថា ការចាប់ផ្តើមនៃរដូវភ្លៀង នឹងមកដល់យឺតជាងមុន។ ការធ្លាក់ភ្លៀងនៅរដូវវស្សានឹងកើនឡើង (នាំមកនូវជំនន់កាន់តែច្រើន) ហើយការធ្លាក់ភ្លៀងនៅរដូវប្រាំងនឹងថយចុះ (នាំឲ្យមានគ្រោះរាំងស្ងួត)។ នៅទីបំផុត ខ្សែឆ្នេរសមុទ្រកម្ពុជាប្រវែង ៤៣៥គ.ម និងមួយផ្នែកធំនៃទំនាបលិចទឹកទន្លេមេគង្គអាចរងគ្រោះដោយសារកំណើនកំពស់ទឹកសមុទ្រ ដែលត្រូវបាននិទស្សន៍ថាធ្វើឲ្យតំបន់ដទៃទៀតរងគ្រោះដោយសារជំនន់ ការជ្រាបចូលនៃទឹកសមុទ្រ និងការជន់លិចតំបន់ឆ្នេរ ដោយនាំមកនូវការពាក់ព័ន្ធអវិជ្ជមានសម្រាប់ទឹកជំនន់ និងសន្តិសុខទឹក និងស្ថិរភាពហេដ្ឋារចនាសម្ព័ន្ធផងដែរ។ |

[6] Kingdom of Cambodia: Mainstreaming Climate Resilience into Development Planning, Project Number: 45283. Capacity Development Technical Assistance (CDTA). September 2012.

ដូច្នេះ ការប្រែប្រួលអាកាសធាតុបង្កជាការគំរាមកំហែងធ្ងន់ធ្ងរមួយចំពោះការអភិវឌ្ឍដោយចីរភាពនៅកម្ពុជា″។

គម្រោង CARP[7] បានសន្មតដូចតទៅ៖

- កំណើនកំពស់ទឹកសមុទ្រ ១៨ ដល់ ៥៦ស.ម រហូតដល់ឆ្នាំ ២០៩០
- កំណើនការធ្លាក់ភ្លៀងនៅតាមឆ្នេរសមុទ្រពី ២ ទៅ ៦% រហូតដល់ឆ្នាំ ២០៥០ និងកំណើនជាលំដាប់នៃភាពញឹកញាប់ និងប្រពលភាពនៃព្រឹត្តិការណ៍ទឹកជំនន់ ដោយសារតែការធ្លាក់ភ្លៀងខ្លាំងញឹកញាប់ជាងមុន
- កំណើនសីតុ. មធ្យមប្រចាំឆ្នាំ ០,៣ ដល់ ០,៦អង្សារ រហូតដល់ឆ្នាំ ២០២៥ កំណើន ០,៧ ដល់ ២,៧អង្សារ រហូតដល់ឆ្នាំ ២០៦០ និងកំណើន ១,៤ ដល់ ៤,៣អង្សារ រហូតដល់ឆ្នាំ ២០៩០។ ប្រការនេះនាំឲ្យមានកំណើនហានិភ័យគ្រោះរាំងស្ងួតជាទៀងទាត់ ក៏ដូចជា កំណើនជាច្រើននៃចំនួនថ្ងៃ និងយប់ ដែល″ក្តៅខ្លាំង″ផងដែរ។

*កំណើនកំពស់ទឹកសមុទ្រ* រួមផ្សំជាមួយការថយចុះនៃវិសាលភាពព្រៃកោងកាង និងកំណើនភាពញឹកញាប់ និងកម្លាំងខ្យល់និងព្យុះសមុទ្រ បាននាំមកនូវការជន់លិចកន្លែងខ្លះក្នុងតំបន់ឆ្នេររួចមកហើយ។ ផលវិបាកគឺ កំណើនកម្រិតប្រៃនៃផ្ទៃដី ក៏ដូចជា ទឹកក្រោមដី ដែលប៉ះពាល់មកលើជីជាតនៃដីដាំដំណាំ ក៏ដូចជា ប្រព័ន្ធអេកូឡូស៊ីដែនទឹកសាបផងដែរ។ ប្រការនេះបង្កជាការគំរាមកំហែងមកលើសន្តិសុខស្បៀង និងការចិញ្ចឹមជីវិត ដោយសារតែកសិកម្មភាគច្រើននៅក្នុងតំបន់ឆ្នេរ ប្រមូលផ្តុំតែក្នុងកន្លែងទំនាបដែលងាយរងគ្រោះពីទឹកជំនន់។ ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ឆ្នេរក៏ស្ថិតក្រោមសម្ពាធផងដែរ ដែលនាំទៅរកកំណើនភាពងាយរងគ្រោះជាបន្តបន្ទាប់ និងការបាត់បង់/រំខានដល់ប្រាក់ចំណូល ដោយសារតែកំណើនភាពមិនអាចចេញចូលបាន។

*កំណើនកំពស់ទឹកភ្លៀង*ជាពិសេសក្នុងតំបន់ឆ្នេរ។ ខ្យល់ព្យុះកើតឡើងស្ទើរតែរាល់ឆ្នាំ ពីពាក់កណ្តាលខែតុលា រហូតដល់ខែធ្នូ។ ទោះជាយ៉ាងណាក៏ដោយ ជាមួយការប្រែប្រួលដែលបង្កឲ្យមានធាតុអាកាសកាន់តែខុសប្លែកពីមុន គេអាចឃើញមានកំណើនព្រឹត្តិការណ៍ទឹកជំនន់កាន់តែញឹកញាប់ និងកាន់តែខ្លាំងជាងមុន។ ទឹកជំនន់ ការធ្លាក់ភ្លៀងខ្លាំង និងខ្យល់ព្យុះបំផ្លាញទ្រព្យសម្បត្តិ និងមធ្យោបាយផលិតកម្ម ដូចជា ដំណាំ និងសត្វចិញ្ចឹម។ ទឹកជំនន់ច្រើនតែបង្កប្រភពទឹកក្លាយជាក្រខ្វក់ និងលក្ខខណ្ឌគ្មានអនាម័យ/មិនស្អាត ដែលបង្កជាបញ្ហាធ្ងន់ធ្ងរចំពោះសុខភាព និងការផ្ទុះនៃជម្ងឺ។ កំណើនភាពញឹកញាប់នៃខ្យល់ព្យុះ ក៏មានឥទ្ធិពលមកលើការដាំដំណាំ ដលផល និងសំណឹកក្នុងតំបន់ឆ្នេរផងដែរ។

*កំណើនសីតុណ្ហភាព* នាំឲ្យមានកំណើនករណីគ្រោះរាំងស្ងួត និងចំនួនថ្ងៃនិងយប់″ក្តៅខ្លាំង″។ គ្រោះរាំងស្ងួតឬរលកកំដៅនឹងបង្កឲ្យខ្វះខាតទឹក។ បញ្ហាទាំងអស់នេះមានឥទ្ធិពលបំផ្លាញមកលើសុខភាពរបស់ប្រជាពលរដ្ឋទាំងមូល ដំណាំ និងសត្វចិញ្ចឹម។ កំណើនសីតុណ្ហភាព ឬ ការកើនឡើងនៃរលកកំដៅ នឹងកាត់បន្ថយផងដែរនូវសមត្ថភាពរបស់ប្រជាជននៅក្នុងការងារ ដោយសារតែកំដៅខ្លាំង។ ទោះបីវាជាកង្វល់តិចតួចនៅក្នុងតំបន់ឆ្នេរក៏ដោយនាពេលបច្ចុប្បន្ននេះ សេណារីយ៉ូនេះអាចកើនឡើង ប្រសិនបើធាតុអាកាសកាន់តែគ្មានលក្ខណៈប្រក្រតី ដែលក្នុងនោះតំបន់ឆ្នេរនឹងងាយរងគ្រោះជាពិសេស។

[7]ការវាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យចំពោះសហគមន៍បណ្តាលពីការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ឆ្នេរកម្ពុជា។ ខែតុលា ឆ្នាំ ២០១២។

**សហគមន៍តំបន់ឆ្នេរ និងការប្រែប្រួលអាកាសធាតុ**

បើគ្មានជំនួយ អ្នកដែលរស់នៅក្នុងតំបន់ឆ្នេរនឹងត្រូវពុះពារដើម្បីបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈកង្វះសមត្ថភាពដើម្បីធ្វើសកម្មភាព ដូចមានចែងនៅក្នុងសំណើគោលនយោបាយថ្មីៗនេះ[8]៖

- កង្វះសមត្ថភាពដើម្បីអនុវត្តសកម្មភាពនេសាទ និងកសិកម្មនៅក្នុងបណ្តាភូមិតាមតំបន់ឆ្នេរ ដើម្បីធានានិរន្តរភាពនៃសន្តិសុខស្បៀង
- កង្វះសមត្ថភាពក្នុងចំណោមអ្នកភូមិក្នុងតំបន់ឆ្នេរ ដើម្បីទទួលបានទឹកគ្រប់គ្រាន់សម្រាប់សកម្មភាពសេដ្ឋកិច្ចនៅក្នុងពេលមានទឹកជំនន់ និងគ្រោះរាំងស្ងួត សម្រាប់បំពេញតម្រូវការក្រៅពីកសិកម្ម
- កង្វះសមត្ថភាពក្នុងចំណោមអ្នកភូមិតាមតំបន់ឆ្នេរក្នុងការកាត់បន្ថយផលប៉ះពាល់នៃគ្រោះរាំងស្ងួតមកលើប្រព័ន្ធផលិតកម្មស្បៀងតាមគ្រួសារ ដើម្បីធានាសន្តិសុខស្បៀងឲ្យបានពេញមួយឆ្នាំ
- កង្វះសមត្ថភាពក្នុងចំណោមអ្នកភូមិក្នុងតំបន់ឆ្នេរ ក្នុងការទទួលបានសេវាអភិវឌ្ឍន៍ឲ្យបានសមស្រប ដូចជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បច្ចេកវិទ្យាចិញ្ចឹមជីវិត និងការអភិវឌ្ឍសមត្ថភាពគ្រប់គ្រងធនធានធម្មជាតិ
- កង្វះសមត្ថភាពក្នុងចំណោមអ្នកភូមិនៅតំបន់ឆ្នេរដើម្បីចូលរួមក្នុងកិច្ចផ្តួចផ្តើមគ្រប់គ្រងធនធាននៅថ្នាក់មូលដ្ឋានក្នុងការទ្រទ្រង់យុទ្ធសាស្ត្រខុសៗគ្នានៃការចិញ្ចឹមជីវិតនៅជនបទ និងតម្រូវការអាហារូបត្ថម្ភប្រចាំគ្រួសារ។

បញ្ហាទាំងអស់នេះមានការពាក់ព័ន្ធសម្រាប់ការកសាងផែនការប្រើប្រាស់ដី ដែលពាក់ព័ន្ធនឹងការចូលរួមរបស់សហគមន៍នៅក្នុងការធ្វើសេចក្តីសម្រេច ដែលទាក់ទងជាមួយ CDPs និង CLUPs និងនៅក្នុងការបង្កើតប្លង់ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាគាំទ្រដទៃទៀតផងដែរ។

**ការកសាងផែនការប្រើប្រាស់ដី និងការប្រែប្រួលអាកាសធាតុ**

ការកសាងផែនការប្រើប្រាស់ដី ទាក់ទងជាចំបងនឹងការកំណត់តំបន់ដីសម្រាប់គោលបំណងខុសៗគ្នា និងទាក់ទងនឹងទីតាំងនៃហេដ្ឋារចនាសម្ព័ន្ធ/សេវានានា ដែលអាចបម្រើការបានល្អបំផុតតបនឹងតម្រូវការបច្ចុប្បន្ន និងទៅ អនាគតរបស់សហគមន៍ និងផលិតផលសាធារណៈទូទៅ (ដូចជា ការកំណត់ព្រំប្រទល់ឧទ្យានជាតិ)។ រួមជាមួយការត្រួតពិនិត្យលើការសាងសង់ គេអាចប្រើប្រាស់ដើម្បីបង្កើតក្របខ័ណ្ឌគតិយុត្តិដែលផ្តល់ជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍផងដែរ។

ក្នុងនេះ អ្នកកសាងផែនការប្រើប្រាស់ដីត្រូវពិចារណាអំពីភាពសមស្របនៃការប្រើប្រាស់ដីបច្ចុប្បន្ន និងវត្តមានដី ជាការពិចារណាគន្លឹះ ដែលជាផ្នែកមួយនៃដំណើរការកសាងផែនការណាមួយ។ ការប្រែប្រួលអាកាសធាតុមានការពាក់ព័ន្ធ ជាមួយចំណុចទាំងពីរ ដោយសារដីអាចលែងមានភាពសមស្រប និង/ឬ លែងមានទៅអនាគត អាស្រ័យលើការប្រែប្រួលជាក់ស្តែងនៃអាកាសធាតុ ដូចជា កំនើនកំពស់ទឹកសមុទ្រ។ ដូច្នេះ អ្នកកសាងផែនការត្រូវគិតថា កត្តាទាំងនេះមិនមែនជាប់នៅមួយកន្លែងនោះទេ និងអាចកែប្រែជាបន្តបន្ទាប់។

ការទទួលស្គាល់អំពីសក្តានុពលនៃទំហំនៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ មានន័យថា ឥឡូវនេះអ្នកកសាង

[8] Climate Change Adaptation Knowledge Platform. Policy Brief: Climate Change Resilience in Coastal Cambodia – Adaptive Capacity and Human Development. 2011.

ផែនការប្រើប្រាស់ដីត្រូវគិតគូរអំពីសេណារីយ៉ូនានាទៅអនាគត ថាតើការអភិវឌ្ឍទៅអនាគតគួរតែធ្វើបែបណា ក៏ដូចជាការពិចារណាអំពីរបៀបទប់ទល់នឹងការគំរាមកំហែងពីការប្រែប្រួលអាកាសធាតុដែលអាចបង្កការប៉ះពាល់មកលើតំបន់ដែលបានអភិវឌ្ឍន៍នាពេលឥឡូវនេះផងដែរ។ វាពិតជាមិនមានប្រយោជន៍ទេក្នុងការកសាងផែនការតំបន់នានាទៅអនាគត តាមទម្រង់ ឬ ទីតាំងណាមួយ ដែលអាចរងគ្រោះទៅអនាគតពីការប្រែប្រួលអាកាសធាតុដែលបាននិទស្សន៍ទាំងនៅក្នុងរយៈពេលខ្លី និងរយៈពេលវែង។

ជម្រើសទៅអនាគត (ដែលមិនបំភ្លេចគ្នាទៅវិញទៅមក) សម្រាប់ទាំងរដ្ឋាភិបាល និងបុគ្គលនានា ដែលទាក់ទងនឹងការកសាងផែនការគឺ៖

- បន្តសកម្មភាពបច្ចុប្បន្ន ជាមួយជម្រើសបន្សុាំនឹងការប្រែប្រួលអាកាសធាតុ ដែលកំហិតត្រឹមវត្ថុមានមូលនិធិនៅប្រភពតាមមូលដ្ឋានសម្រាប់កែលម្អជាបន្តបន្ទាប់នៃប្រព័ន្ធដែលមានបច្ចុប្បន្ននៃការផ្គត់ផ្គង់ទឹក កិច្ចការពារតំបន់ឆ្នេរ និងលទ្ធភាពក្នុងការចេញចូល ជាមួយការសាកល្បងខាងរបរចិញ្ចឹមជីវិត (រយៈពេលខ្លី នៅមូលដ្ឋាន និងកំណើនជាបណ្តើរៗ។)
- ទទួលស្គាល់ពីតម្រូវការ ជំនួយពីខាងក្រៅ (បច្ចេកទេស/ហិរញ្ញវត្ថុ) តាមរយៈការកែប្រែរបរចិញ្ចឹមជីវិត ដើម្បីបន្សុាំទៅនឹងកាលៈទេសៈប្រែប្រួល (ដូចជាការផលិតចម្រុះស្រូវ/បង្គារ)។ ហេដ្ឋារចនាសម្ព័ន្ធកាន់តែរឹងមាំ ដែលរួមទាំងសម្រាប់ការផ្គត់ផ្គង់ទឹក និងការពារតំបន់ឆ្នេរ៖ ការកែលម្អផ្ទះនីមួយៗ ដើម្បីបន្សុាំបានកាន់តែប្រសើរទៅនឹងការប្រែប្រួលអាកាសធាតុ (រយៈពេលមធ្យម ខាងក្រៅ និងមានការវិវត្តន៍បណ្តើរៗ)
- ប្តូរទីតាំងទ្រព្យសម្បត្តិ និងហេដ្ឋារចនាសម្ព័ន្ធខ្លះៗទៅទីតាំងនានាដែលអាចការពារបានជាងមុនពីកំណើនផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ប៉ុន្តែត្រូវប្រើប្រាស់ឱកាសនានា ដើម្បីបង្កើតតាមរយៈការដកថយខ្សែឆ្នេរសមុទ្រ ឬ ការរក្សាប្រព័ន្ធឧបករណ៍ការពារឆ្នេរ (រយៈពេលវែង ជាយុទ្ធសាស្ត្រ និងការប្តូរទីតាំង)។

ទោះជាយ៉ាងណាក៏ដោយ សម្រាប់បុគ្គលម្នាក់ៗ ឬ គ្រួសារ មិនគួរចាត់ទុកជម្រើសទាំងនេះថាត្រូវយកលំនាំតាមគ្នាទៅវិញទៅមកនោះទេ។ វិធានបន្សុាំសម្រាប់រយៈពេលខ្លីរបស់បុគ្គលម្នាក់ អាចស្រដៀងគ្នានឹងដំណោះស្រាយរយៈពេលវែងសម្រាប់បុគ្គលផ្សេងទៀត។ មនុស្សជាច្រើនបានចាកចេញពីតំបន់ឆ្នេររួចទៅហើយ ទៅកន្លែងដែលពួកគេយល់ថាជាទីតាំងដែលមានសុវត្ថិភាព ចំណែកអ្នកដទៃទៀតបានត្រៀមខ្លួនកាន់តែច្រើន ឬ លះបង់ការបន្ត និងបន្សុាំជាបន្តបន្ទាប់ទៅនឹងការប្រែប្រួលកាលៈទេសៈ។

ប៉ុន្តែរដ្ឋាភិបាល និងជាពិសេស អ្នកកសាងផែនការត្រូវតែថ្លឹងថ្លែងថ្លៃចំណាយ និងផលចំណេញនៃការបន្តស្ថិតនៅនិងការពារ ធៀបនឹងការជំទាស់ទៅនឹងការប្តូរទីតាំង និងការកសាងឡើងវិញ។ ឧទា. អំណះអំណាងខាងហិរញ្ញវត្ថុ និងសេដ្ឋកិច្ចនៅក្នុងការសម្រេចកសាងទំនប់រលកប្រវែង ៥គ.ម ដើម្បីការពារផ្ទាល់ប្រជាជន ២០០គ្រួសារពីកំណើនកំពស់ទឹកសមុទ្រ គឺជាបញ្ហាស្មុគស្មាញ។ អ្នកផ្តល់សេវាសាធារណៈទាំងអស់ បើទោះជាផ្លូវថ្នល់ បង្គោលខ្សែភ្លើង ឬ អគារ ត្រូវតែគិតគូរអំពីការវាយតម្លៃខ្លះៗអំពីកំណើនកំពស់ទឹកសមុទ្រដែលរំពឹងទុក នៅក្នុងអាយុកាលនៃរចនាសម្ព័ន្ធនោះផងដែរ។

ការធ្វើសេចក្ដីសម្រេចណាមួយ កាន់តែមានលក្ខណៈជាយុទ្ធសាស្ត្រ និងសម្រាប់រយៈពេលវែង ប្រសិនបើត្រូវពិចារណាអំពីផលប៉ះពាល់ដែលរំពឹងថាកើតចេញពីការប្រែប្រួលអាកាសធាតុ និងធ្វើការជ្រើសយករវាងបន្តនៅនឹងកន្លែង និងការប្តូរទីកន្លែងទៅកេទីតាំងដែលកាន់តែសមស្របៗការសម្រេចទាំងនេះនឹងពាក់ព័ន្ធជាមួយការវិភាជន៍ទឹកប្រាក់យ៉ាងច្រើនសម្រាប់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសេវានានាពីសំណាក់រដ្ឋាភិបាល និងមានឥទ្ធិពលដោយផ្ទាល់មកលើវិស័យឯកជន និងបុគ្គលនានានៅក្នុងការជ្រើសរើសរបស់ពួកគេអំពីកន្លែងរស់នៅធ្វើការ និងលេង។

**ភាពតភ្ជាប់គ្នារវាងទីជនបទ និងទីក្រុង**

តំបន់ឆ្នេរផ្សំដោយការប្រើប្រាស់ដីចម្រុះ ពីតំបន់ទីក្រុងធំៗ រហូតដល់ភូមិតូចៗ និងពីព្រៃកោងកាង នៅតាមជាយដីស្រែ រហូតដល់ព្រៃធម្មជាតិតាមទីខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ វាមានការទាក់ទងរវាងគ្នា។ ទីក្រុងមាននាទីជាមធ្យោបាយសម្រាប់លក់ផលិតផលពីជនបទ ផ្ទុយមកវិញផ្តល់សេវាប្រមូលផ្តុំ ដែលប្រើប្រាស់ដោយអ្នកទាំងឡាយដែលរស់នៅតាមជនបទ។ ម្យ៉ាងវិញទៀត មានការចាំបាច់ដើម្បីផ្សារភ្ជាប់អ្វីដែលបានគ្រោងទុក និងអនុវត្តនៅតាមទីក្រុង ជាមួយសកម្មភាពនានានៅជនបទ ដែលគាំទ្រដល់មុខងារនៃទីក្រុង។ ទន្ទឹមនឹងនេះ ប្រសិនបើសកម្មភាពនៅជនបទរងឥទ្ធិពលពីកំណើនកំពស់ទឹកសមុទ្រ ឬ កំណើនកម្រិតប្រៃ ត្រូវបញ្ចូលប្រការនេះទៅក្នុងផលិតកម្ម ប្រាក់ចំណូល ការងារ និងការវិនិយោគ និងមានឥទ្ធិពលដោយផ្ទាល់មកលើសុខុមាលភាពរបស់អ្នករស់នៅទីក្រុង។

មិនដូចទីក្រុងឡើយ ប្រជាជនភាគច្រើនរស់នៅតាមទីតាំងគម្រោងក្នុងតំបន់ឆ្នេរ ពឹងផ្អែកជាខ្លាំង និងដោយផ្ទាល់លើកសិកម្ម ដូច្នេះគេអាចមានការរំពឹងទុកពីការប្រែប្រួលអាកាសធាតុប្រចាំរដូវ ជាពិសេសរបបទឹកភ្លៀង។ កង្វះទឹកសាប ឬការផ្គង់ផ្គង់ដែលមិនទៀងទាត់/ខុសពីប្រក្រតី តែងតែមានការពាក់ព័ន្ធធ្ងន់ធ្ងរសម្រាប់របរចិញ្ចឹមជីវិត និងសមត្ថភាពផ្ទាល់របស់ប្រជាជនក្នុងការបន្តរស់នៅទីនោះ។ ភាពធន់នៃប្រជាពលរដ្ឋទាំងនោះនឹងស្ថិតក្រោមការសាកល្បងបន្ថែមទៀតដោយកំណើនកំពស់ទឹកសមុទ្រ ជាមួយកំណើនដែលពាក់ព័ន្ធនៃកម្រិតប្រៃប្រចាំរដូវនៃផ្លូវទឹក និងប្រភពទឹកសម្រាប់ការផ្គត់ផ្គង់។ នេះជាបញ្ហានៅក្នុងរដូវប្រាំង និងមានន័យថា ទឹកផឹក ត្រូវតែទិញពីកន្លែងផ្សេង និងរបរចិញ្ចឹមជីវិតជំនួសការធ្វើស្រែ ក៏ជាចំណុចដែលត្រូវសិក្សាផងដែរ។ លើសពីនេះផលប៉ះពាល់ដែលអាចកើតចេញពីព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី អាចកាន់តែមហាបំផ្លាញ ជាងព្រឹត្តិការណ៍ប្រែប្រួលអាកាសធាតុដែលកាន់តែធ្ងន់ធ្ងរ ដូចជា ការរំពឹងទុកអំពីកំណើនកំពស់ទឹកសមុទ្រក្នុងពេលបច្ចុប្បន្ននេះ។ ដូច្នេះ កិច្ចផ្តួចផ្តើមគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ (DRM) អាចក្លាយជាអាទិភាពកាន់តែខ្ពស់ទៅអនាគត ប្រសិនបើភាពញឹកញាប់/ទំហំ/រយៈពេលនៃព្រឹត្តិការណ៍បែបនេះកាន់តែកើនឡើង[៩]។

ស្ថានភាពនេះបានរួមចំណែកក្នុងការធ្វើឲ្យមានចំណាកស្រុកយ៉ាងច្រើនទៅទីក្រុងដើម្បីស្វែងរកការងារដែលល្អៗជាង និងមិនសូវត្រូវការកម្លាំងកាយខ្លាំង។ ក្នុងរយៈពេល ១០ ឆ្នាំកន្លងមក ប្រជាជនតាមទីក្រុងនៅកម្ពុជា បានកើន

[៩]បញ្ហាភាពញឹកញាប់នៃព្រឹត្តិការណ៍នានាទាមទារឲ្យមានការសិក្សាបន្ថែមទៀត ទោះបីព្រឹត្តិការណ៍ធាតុអាកាសបែបនោះនឹងអាចកើតឡើងកាន់តែញាប់ញាប់ (អាចម្តងក្នុងរយៈពេល ១០ឆ្នាំ) ជំនួសឲ្យរៀងរាល់ ៥០ឆ្នាំ។ ព័ត៌មានបែបនេះនឹងមានឥទ្ធិពលជាខ្លាំងមកលើសេចក្តីសម្រេចធ្វើវិនិយោគរបស់រដ្ឋាភិបាល និងការបង្កើតស្តង់ដារនៅក្នុងតំបន់រងគ្រោះ (ការពារ បន្សាំ ឬប្តូរទីកន្លែង) និងមកដល់អ្នកជំនួយ និងប្រជាជនផងដែរ។

ឡើងតាមអត្រារវាង ៣,៩ និង ៤,៥ (AAGR ២០០៣-២០១០)។ ទីជនបទនៃខេត្តកោះកុង និងខេត្តព្រះសីហនុ (ដែលមានឃុំទាំង ៨ ជាគោលដៅ) បានកើនឡើងតាមអត្រា ១,៤-២,១ នៅក្នុងអំឡុងឆ្នាំ ១៩៩៨-២០០៨។ ប្រាក់ចំណូលនៅជនបទបានកើនឡើងយឺត ហើយឥឡូវនេះមួយផ្នែកធំនៃប្រាក់ចំណូលនៅតាមជនបទ បានមកពីប្រភពមិនមែនកសិកម្ម ដូចជា ការងារក្នុងវិស័យសេវា (ដែលរួមទាំង ទេសចរណ៍) និងប្រាក់ដែលសមាជិកគ្រួសាររស់នៅកន្លែងផ្សេងផ្ញើមកផ្ទះ។ នេះជាករណីដែលកើនឡើងកាន់តែច្រើនសម្រាប់ប្រជាជនតាមជនបទដែលមិនអាចរស់នៅពឹងផ្អែកតែលើកសិកម្មតាមប្រពៃណី និងសកម្មភាពផ្សេងទៀតនៅជនបទ។

**ការបន្សុាំ**

នៅតាមទីក្រុង វិធានការបន្សុាំដែលអាចអនុវត្តបាន ច្រើនតែទាក់ទងនឹងការថែរក្សាបរិស្ថានដែលបានសាងសង់និងពាក់ព័ន្ធជាមួយចំនួនមនុស្សយ៉ាងច្រើនដែលមានស្ថានភាពប្រហាក់ប្រហែលគ្នា។ប៉ុន្តែ នៅតាមតំបន់ឆ្នេរ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុអាចឆ្លុះបញ្ចាំងតាមរយៈការប្រែប្រួលនៃស្ថានភាពដី (ដូចជា តាមរយៈសំណឹក កំណើនជាតិប្រៃ) របរចិញ្ចឹមជីវិត (ដូចជា ការប្តូរពីដំណាំស្រូវមកចិញ្ចឹមបង្គារ) ក៏ដូចជា ភាពខុសៗគ្នានៃហេដ្ឋារចនាសម្ព័ន្ធ និងសេវា (ដូចជា អណ្តូងដែលមានទឹកមិនស្អាត ឬ សម្ពាធមកលើទំនប់)។

នៅតាមទីក្រុង កំណើនចំនួនប្រជាជន និងការវិនិយោគមានន័យថា ការបន្សុាំជាងការប្តូរទីតាំង គួរតែជាជម្រើសដែលប្រកាន់យក។ តាមទីជនបទក្នុងតំបន់ឆ្នេរ ការគ្រោងសម្រាប់ភាពធន់នឹងអាកាសធាតុអាចត្រូវចំណាយច្រើនដោយសារតែប្រជាជនដែលពាក់ព័ន្ធមានចំនួនតិច និងក្នុងករណីដែលមិនអាចបញ្ចុះបញ្ចូលពួកគេឲ្យស្ថិតនៅកន្លែងដដែល ទៅតាមការវិនិយោគបន្សុាំណាមួយ។

ប៉ុន្តែ ការប្រែប្រួលអាកាសធាតុគ្រាន់តែជាកត្តាមួយក្នុងចំណោមកត្តាមួយចំនួនដែលមានឥទ្ធិពលមកលើការធ្វើសេចក្តីសម្រេចលើការកសាងផែនការប្រើប្រាស់ដីប៉ុណ្ណោះ។ កត្តាដទៃទៀត ដូចជា គោលនយោបាយសេដ្ឋកិច្ច-សង្គមរបស់រដ្ឋាភិបាល និងផែនការវិនិយោគទំនងជាមានសារៈសំខាន់ជាង។ នៅតាមជនបទ កម្មសិទ្ធិដីអាចជាកត្តាសំខាន់បំផុតនៅក្នុងការសម្រេចអំពីការអភិវឌ្ឍ។ ដូច្នេះ ទោះបីគោលការណ៍ណែនាំនេះមានបំណងរួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងការប្រើប្រាស់ដីក៏ដោយ គេមិនគួរសន្មតថា ការពិចារណាអំពីការប្រែប្រួលអាកាសធាតុផ្ទាល់គឺជាកត្តាចំបងដែលកំណត់លើការសម្រេចនោះឡើយ។

**ដំណើរការ**

គំរូខ្លះនៃការប្រែប្រួលអាកាសធាតុបាននិទស្សន៍អំពីកំណើនកំពស់ទឹកសមុទ្ររហូតដល់ ១ម រហូតដល់ចុងសតវត្សរ៍នេះ។ ដោយប្រើប្រាស់ព័ត៌មានស្ថានភាពដីដែលទទួលបាន អ្នកត្រូវព្យាយាមពិចារណាអំពីស្ថានភាពនៃកំណើនកំពស់ទឹកសមុទ្រជាមធ្យម ១៥០ស.ម។ ក្នុងនាមជាអ្នកកសាងផែនការ និងប្រសិនបើស្ថានភាពនេះកើតឡើង អ្នកត្រូវធ្វើការសម្រេចថាតើឃុំអាចនៅបន្តដំណើរការបែបណា។ ចូរពិនិត្យមើលទិន្នន័យដែលមាន សម្រាប់ឃុំរបស់អ្នក និងអនុវត្តកិច្ចការដូចតទៅ៖

| ការប្រែប្រួលអាកាសធាតុ |
|---|
| • រកមើលគ្រប់ទីកន្លែងដែលមានកំពស់ខ្ពស់ជាង ១៥០ស.ម ធៀបនឹងកំពស់ទឹកសមុទ្របច្ចុប្បន្ន<br>• សម្រេចថាតើក្រុមប្រជាពលរដ្ឋណាខ្លះអាចត្រូវបន្សាំ ឬ ត្រូវជម្លៀស<br>• តើត្រូវការឲ្យមានអ្វីខ្លះដើម្បីប្រជាជនអាចបន្សាំ និងមិនជម្លៀស?<br>• កំណត់អត្តសញ្ញាណចំណែកដីណាខ្លះដែលសមស្រប និងមានសម្រាប់ការប្តូរទីលំនៅ?<br>• កំណត់ថាតើសាលារៀន គ្លីនិក ផ្សារណាខ្លះ ដែលអាចត្រូវប្តូរទីតាំង?<br>• លើកស្ទួយបរចិញ្ចឹមជីវិតដែលសមស្របសម្រាប់អ្នកដែលរស់នៅក្នុងឃុំ នៅក្នុងស្ថានភាពបែបនេះ។ |

# ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ

| លទ្ធផលរំពឹងទុក |
|---|
| • ការពិនិត្យមើលកម្រិតត្រៀមលក្ខណៈរបស់ឃុំសម្រាប់ករណីនៃព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី |
| **វត្ថុមានទិន្នន័យ** |
| យោបល់ពីតំណាងឃុំអំពីផែណការបច្ចុប្បន្ន និងនីតិវិធីនានា |
| **ព័ត៌មាន** |
| ព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី រួមមាន ខ្យល់ព្យុះ ទឹកជំនន់ ស៊ីក្លូន និង/ឬ អគ្គីភ័យ ដែលអាចកើតឡើងតាមរដូវ ឬ ម្តងម្កាល។ បើប្រៀបធៀបជាមួយការប្រែប្រួលសន្សឹមៗនៃអាកាសធាតុ ព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតីតាមធម្មតាព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតីកើតឡើងរយៈពេលខ្លី ប៉ុន្តែមានសក្តានុពលក្នុងការធ្វើឲ្យខូចខាតធំធេងដល់គោលដៅខ្លះៗ ដូចជា ផលប៉ះពាល់រយៈពេលវែងផងដែរ។ ជាពិសេស ស្ថានភាពបែននេះកើតឡើងសម្រាប់អ្នកដែលរស់នៅក្នុងអគារទ្រុឌទ្រោម នៅទីទំនាបក្នុងតំបន់ឆ្នេរ ដែលងាយរងផលប៉ះពាល់ដោយសារទាំងទឹក និងខ្យល់។ |
| **ដំណើរការ** |
| ពិនិត្យមើលនីតិវិធីដែលមាននៅនឹងកន្លែងសម្រាប់ឃុំ ដែលត្រូវព្រមានជាមុន និងត្រូវបញ្ជូនព័ត៌មានអំពីព្រឹត្តិការណ៍ធាតុអាកាសដែលរំពឹងថាកើតមាន។ ជាពិសេស ត្រូវពិនិត្យមើលៈ<br>• តើមាននីតិវិធីអ្វីខ្លះសម្រាប់ឃុំ ដើម្បីទទួលព័ត៌មានព្រមានជាមុនអំពីព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតីដែលរំពឹងថាកើតមាន (ដូចជា ស៊ីរ៉ែន ទូរស័ព្ទចល័ត សារអេឡិចត្រូនិក)?<br>• តើមេដឹកនាំឃុំណាខ្លះ បញ្ជូនសារព្រមានដល់ប្រជាជន?<br>• តើសកម្មភាពអ្វីខ្លះដែលផែនការប្រកាសឲ្យដឹងជាមុន/ការបណ្តុះបណ្តាលលើកស្ទើសម្រាប់ករណីដែលមានព្រឹត្តិការណ៍មិនប្រក្រតី (ដូចជា ច្រកបណ្តោះខ្លួន អគារដែលកំណត់ថាមានសុវត្ថិភាពសម្រាប់ការជ្រកកោណ |

| |
|---|
| ចំណុចដែលអ្នកភៀសខ្លួនត្រូវជួបគ្នា ការទទួលខុសត្រូវសម្រាប់ការភៀសខ្លួន)?<br>• តើអាចកែលម្អប្រព័ន្ធដែលមានស្រាប់ដែរឬទេ បើអាចតើកែលម្អដោយរបៀបណា?<br>• តើហេដ្ឋារចនាសម្ព័ន្ធ/សម្បទានានាត្រូវកែលម្អបែបណា ជាពិសេសសម្រាប់ដោះស្រាយបញ្ហាព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតីដែលអាចកើតមាន? |

# ធាតុចូលសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ឃុំ

| |
|---|
| **លទ្ធផលរំពឹងទុក** |
| • ផែនទីមួយ និងសេចក្តីអធិប្បាយអំពីគម្រោងទៅអនាគត ដែលឃុំបានចាត់ទុកថាពាក់ព័ន្ធក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ និងព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតីនៅក្នុងតំបន់នេះ។ |
| **វត្ថុមានទិន្នន័យ** |
| ផែនទីនានាដែល CARP បានផ្តល់ឲ្យពីមុនមក ដែលនៅលើនោះឃុំបានបន្ថែមបញ្ហាដែលខ្លួនបានកំណត់ឃើញរួមជាមួយ ការងារបន្ថែមណាមួយដែលបានរៀបចំឡើងនៅក្នុងវគ្គបណ្តុះបណ្តាលនេះ |
| **ព័ត៌មាន** |
| ឥឡូវនេះអ្នកបានធ្វើការលើទិន្នន័យស្ថិតិ ផែនទី និងចំណេះដឹងថ្នាក់ខេត្ត/មូលដ្ឋាន ដើម្បីស្វែងយល់អំពីថាតើ ឃុំរបស់អ្នកប្រតិបត្តិការបែបណា ជាផ្នែកមួយនៃស្រុក/ខេត្ត និងតើមានការប្រឈមអ្វីខ្លះទៅអនាគតសម្រាប់ឃុំរបស់អ្នកបន្តដំណើរការដោយជោគជ័យ។ នៅក្នុងជំពូកចុងក្រោយនេះនៃគោលការណ៍ណែនាំនេះ អ្នកត្រូវពិនិត្យមើលការកសាងផែនការអភិវឌ្ឍន៍ឃុំរបស់អ្នកក្នុងពេលបច្ចុប្បន្ន និងគម្រោងគាំទ្រនានា ធៀបនឹងចំណុចទាំងអស់ដែលបានពិភាក្សារួចមកហើយ។<br><br>ស្របជាមួយគម្រោង CARP តំណាងឃុំបានកំណត់ និងចុះក្នុងផែនទីរួចមកហើយនូវទីតាំងនៃសំណើគម្រោងអាទិភាព ដែលពួកគេជឿថានឹងដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ឧទាហរណ៍ដែលមានខាងក្រោម (រូបទី ១០) បានមកពីមណ្ឌលសីមា ដែលឃុំគោលដៅបានកំណត់ឃើញគម្រោងមួយចំនួនដែលទាក់ទងនឹងធនធានទឹកដែលទាក់ទងភាគច្រើនជាមួយការពង្រីកសមត្ថភាពផ្តល់ទឹកស្អាតឲ្យបានកាន់តែច្រើនខែនៅក្នុងរដូវប្រាំង។ |

រូបទី ១០. សំណើគម្រោងអាទិភាពនៅក្នុងឃុំសាកល្បងមណ្ឌលសីមា



| **ដំណើរការ** |
|---|
| ផ្អែកលើការពិភាក្សានានានៅក្នុងវគ្គបណ្តុះបណ្តាល ក៏ដូចជា ចំណេះដឹងដែលបានកំណត់ពីខាងដើម អ្នកត្រូវ៖ |
| **គោលនយោបាយ ផែនការ គម្រោង និងការប្រែប្រួលអាកាសធាតុ** |
| • យោងទៅគម្រោងដែលស្នើឡើងណាមួយនៅថ្នាក់ជាតិ/ខេត្ត/ស្រុក ដែលអាចមានការពាក់ព័ន្ធសម្រាប់ឃុំនេះ<br>• ពិនិត្យឡើងវិញគម្រោងនានាដែលបានលើកស្នើកន្លងមក ដែលឃុំបានចាត់ទុកថាជាអាទិភាពនៅក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ និងកង្វល់នៃព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតីនៅក្នុងតំបន់នេះ<br>• កែសម្រួល/បន្ថែមទៅក្នុងគម្រោងអាទិភាព ដោយផ្អែកលើចំណេះដឹងដែលទទួលបាន ជាផ្នែកមួយនៃដំណើរការបណ្តុះបណ្តាល<br>• ផ្តល់តួលេខអំពីថ្លៃចំណាយទូលាយ (ដូចជា <១០.០០០ដុល្លា ឬ ច្រើនជាងនេះ ដែលជិតដល់ ១០.០០០ដុល្លា និងលើកស្នើគម្រោងជាដំណាក់កាល<br>• លើកស្នើសកម្មភាពនានាដទៃទៀត (ដូចជា ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ការសិក្សានានា) ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ឬ ធាតុអាកាសមិនប្រក្រតី ដែលអាចដល់ជាប្រយោជន៍ដល់ឃុំនេះ។ |